# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម

សំណុំរឿង០០២ ▪ របាយការណ៍លេខ ៣៣ ▪ សវនាការលើភស្តុតាង ▪ សប្ដាហ៍ទី២៨ ▪២០-២៣ សីហា ២០១២



ករណីរបស់ជនជាប់ចោទលោក នួនជា លោកខៀវ សំផន និងលោកអៀង សារី

**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ជាការពិតណាស់ ដែលថាកន្លែងនេះមិនមែនជាកន្លែងសមស្របទេ ក្នុងការដែលឲ្យសាក្សីនេះ អាន អំពីព័ត៌មាន ដែលដឹងអំពីព័ត៌មានទាក់ទងនឹងគ្រួសាររបស់គាត់... ហើយអ៊ីចឹង សូមឲ្យតុលាការ ប្រព្រឹត្តទៅលើបុគ្គលគ្រប់រូបនៅក្នុងសាលសវនាការនេះ ឲ្យគិតអំពីសិទ្ធិរបស់គាត់ ហើយសិទ្ធិជាឯក ជនរបស់គាត់ទាំងអស់គ្នា។*

\- លោកស្រី **អង់តា ហ្គីសសេ**

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន**

## ផ្នែកទី១ ៖ និដ្ឋភាពទូទៅ

ដោយមានការខ្វះខាតពីសំណាក់អង្គជំនុំជម្រះក្នុងការពន្លឿនដំណើរការនីតិវិធី សក្ខីកម្មបួន ត្រូវបាន ធ្វើឡើងពេញមួយសប្ដាហ៍។ លោក **សួង ស៊ីគឿន** ជាកម្មាភិបាលជាន់ខ្ពស់នៃក្រសួងការបរទេស និងលោក ស្រី **ស សៀក** ជាអ្នកសិល្បៈនៃក្រសួងឃោសនាការ និងអប់រំ បានបញ្ចប់សក្ខីកម្មរបស់ពួកគាត់ ដែលបានធ្វើ កាលពីសប្តាហ៍មុន។ សាក្សីថ្មីមួយរូបទៀតគឺ លោក **គឹម វុន** បានផ្តល់សក្ខីកម្មពីបទពិសោធន៍របស់គាត់ជា ក្មេងធ្វើការនៅក្នុងផ្ទះបោះពុម្ពរបស់បក្ស ហើយក្រោយមកជាអ្នកថតរូប និងអ្នកនិពន្ធក្នុងក្រសួងឃោសនាការ និងអប់រំ។ **គឹម វុន** បានបញ្ចប់សក្ខីកម្មរបស់គាត់ក្នុងសវនាការរយៈពេលពីរថ្ងៃ ដោយទុកពេលឲ្យអង្គជំនុំ ជម្រះចាប់ផ្តើមស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោក **អែម អឿន** ដែលជាគ្រូពេទ្យក្នុងអំឡុងរបប កម្ពុជាប្រជាធិបតេយ្យ។ គាត់បានផ្តល់សក្ខីកម្មអំពីការអនុវត្តន៍វិជ្ជាពេទ្យក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយដែលបានដាក់ឲ្យអនុវត្តក្នុងសម័យនោះ។

## ផ្នែកទី២ ៖ សេចក្តីសង្ខេបសក្ខីកម្មរបស់សាក្សី

មេធាវីការពារក្តីបានបន្តការសាកសួរដេញដោលរបស់ពួកគេ ទៅកាន់សាក្សីពីររូបដែលបានផ្តល់សក្ខី កម្មកាលពីសប្តាហ៍មុន សវនាការស្តាប់សក្ខីកម្មពីបញ្ញវន្ត និងអ្នកតាំងនាមខ្លួនឯងជាប្រវត្តិវិទូ **សួង ស៊ីគឿន** និង អ្នកសិល្បៈ **ស សៀក**។ សាក្សីថ្មីពីររូបក៏បានមកធ្វើសក្ខីកម្មផងដែរ ៖ លោក **គឹម វុន** បុគ្គលិកធ្វើការផ្នែកតស៊ូ

សារព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យ និងដើមបណ្តឹងរដ្ឋប្បវេណី **អែម អឿន** ជាអ្នកជំនាញវិជ្ជាពេទ្យខ្មែរក្រហមទីមួយ ដែលមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

### ក. សក្ខីកម្មរបស់ សួង ស៊ីគឿន

អតីតប្រធានផ្នែកសារព័ត៌មាន និងឃោសនាការនៃក្រសួងការបរទេស **សួង ស៊ីគឿន** ត្រូវបានសួរដេញដោលដោយមេធាវីអន្តរជាតិការពារក្តីរបស់ **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** កាលពីថ្ងៃចន្ទ។ សាក្សីត្រូវបានសាកសួរពីសក្ខីកម្មដែលគាត់បានផ្តល់កាលពីសប្តាហ៍មុនៗ ទាក់ទងនឹងរចនាសម្ព័ន្ធក្រសួងការបរទេស និងដំណើរការនៃការធ្វើសេចក្តីសម្រេច ក៏ដូចជាទំនាក់ទំនងរបស់គាត់ជាមួយមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

#### *ក.១. ការយល់ស៊ីជម្រៅនៃអំណាច ប៉ុល ពត*

**សួង ស៊ីគឿន** បានប្រាប់ថា គាត់បានស្គាល់ **ប៉ុល ពត** តាំងពីឆ្នាំ១៩៥៦ នៅពេលដែលពួកគេទាំងពីរបានបង្រៀននៅ*អនុវិទ្យាល័យចំរើនវិជ្ជា*។ គាត់បានបង្រៀនប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ ខណៈដែល **ប៉ុល ពត** បង្រៀនអក្សរសាស្ត្របារាំង។ គាត់បាននិយាយថា គាត់គ្រាន់តែបានដឹងថា **ប៉ុល ពត** ជាលេខាបក្សពេលដែលគាត់បានចូលបក្សកម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៧១។ សាក្សីបានរៀបរាប់ថា **ប៉ុល ពត** "គាត់មានរូបរាងស្អាតណាស់ ហើយគាត់គួរសមណាស់" ហើយបានបន្ថែមថា "គ្មានអ្នកណាស្មានថា គាត់ទៅប្រែក្លាយទៅធ្វើជាលេខារបស់បក្ស អត់មានអ្នកក្រៅស្មានទេ"។ យោងតាម **សួង ស៊ីគឿន** "ក្រោយពីជ័យជម្នះនៅឆ្នាំ១៩៧៥ មក គឺគាត់ (**ប៉ុល ពត**) គិតថា អ្វីដែលគាត់គិតហ្នឹងគឺថាមិនខុសទេ គោលជំហររបស់គាត់មិនខុសទេ" ហើយគាត់បានបដិសេធរាល់គំនិតដែលផ្ទុយ។ សាក្សីបាននិយាយថា ដូច្នេះការកំណត់គោលការណ៍បក្សនាពេលនោះ គឺពឹងផ្អែកទាំងស្រុងទៅលើមនុស្សម្នាក់។ គាត់បានប្រកាសថា "ហេតុនេះហើយបានជាមានការថ្លោះធ្លោយមានកើតឧក្រិដ្ឋកម្មយ៉ាងធំធេងដូច្នេះ -- ដែលនាំឲ្យមានវិនាសកម្មដូច្នេះ"។

ក្នុងគោលបំណងបង្ហាញទំនោររបស់ **ប៉ុល ពត** នៃ "ការគ្រប់គ្រងយ៉ាងល្អិតល្អន់" **កាណាវ៉ាស** បានលើកយកសេចក្តីថ្លែងការណ៍របស់សាក្សីសាជាថ្មីម្តងទៀត បង្ហាញពីរបៀបដែល **ប៉ុល ពត** បានធ្វើការសម្រេចចិត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យោងតាមសាក្សី **សួង ស៊ីគឿន** លោក **ប៉ុល ពត** "ជាមនុស្សគ្រប់គ្រងល្អិតល្អន់" ហើយ "មិនទុកចន្លោះឲ្យអ្នកដទៃទេ គឺថាតឹងរ៉ឹង"។ គាត់បានអះអាងថា តាំងពី**ប៉ុល ពត** ទទួលខុសត្រូវអត្ថបទ*សៀវភៅខ្មៅ*[1] **អៀង សារី** និងថ្នាក់ដឹកនាំផ្សេងទៀតមិនមានសិទ្ធិសរសេរវាទេ។ ជាងនេះទៅទៀត សាក្សីបានអះអាងថា **ប៉ុល ពត** បានបញ្ជាឲ្យបំពេញការងារមួយចំនួននៅក្រសួងការបរទេសតាមរយៈក្មួយប្រុសរបស់គាត់ **សាឡុត បាន**[2] ដែលជាលេខាធិការដ្ឋានក្រសួង។ ក្នុងនាមជាលេខាបក្ស **ប៉ុល ពត** ទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ៖ សាក្សីបានចងចាំថា **ប៉ុល ពត** "មានសិទ្ធិស្វ័យប្រវត្តិដើម្បីនឹងដឹកនាំ ហើយត្រួតត្រាលើកិច្ចការទាំងអស់របស់បក្សក៏ដូចជារបស់រដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។"

ជាងនេះទៅទៀត **កាណាវ៉ាស** បានលើកពីសក្ខីកម្មរបស់ **សួង ស៊ីគឿន** ឡើងវិញ ដែលចង្អុលបង្ហាញពីតួនាទីរបស់ **អៀង សារី** ជា "អ្នករដ្ឋបាល" មួយរូប ដែលគ្រាន់តែមើលការខុសត្រូវកម្មាភិបាល។ សាក្សីបានគូសបញ្ជាក់ថា ពេលគណៈអចិន្ត្រៃយ៍តែងតាំង និងមើលការខុសត្រូវកម្មាភិបាលក្នុងក្រសួងការបរទេស **ប៉ុល ពត** ជាអ្នកសម្រេចចិត្តចុងក្រោយគេបង្អស់ទៅលើការតែងតាំង ជាពិសេសតំណែងនៅបរទេស។[3] **សួង ស៊ីគឿន** បាននិយាយថា "ក្រសួងការបរទេសគ្រាន់ជាការឆ្លងកាត់ទេ មិនមែនជាអ្នកសម្រេចអីទាំងអស់ទេបាទ"។ ពេលត្រូវបានសង្កត់សួរបន្ថែម សាក្សីបានអះអាងសេចក្តីថ្លែងការណ៍របស់គាត់ជាមួយចៅក្រមស៊ើបអង្កេតក្នុងឆ្នាំ២០០៩ ដែលគាត់បាននិយាយថា ការតែងតាំងទូត មិនត្រូវបានសម្រេចដោយក្រសួងការបរទេសទេ "គឺជាសេចក្តីសម្រេចរបស់មន្ទីរ៨៧០ ឬសេចក្តីសម្រេចរបស់ **ប៉ុល ពត**"។

## *ក.២. ការដោះស្រាយសេចក្តីថ្លែងការណ៍ដែលផ្ទុយនឹងសក្ខីកម្មសាក្សីផ្សេងទៀត*

**កាណាវ៉ាស** បានសាកសួរដេញដោលសាក្សី **សួង ស៊ីគឿន** ជាមួយសេចក្តីថ្លែងការណ៍របស់សាក្សីមុនៗ ដែលផ្ទុយនឹងសក្ខីកម្មរបស់គាត់។ មេធាវីការពារក្តីបាននិយាយថា ដោយយោងតាមសក្ខីកម្មរបស់ **សួរ ហុង** (ក៏ត្រូវបានស្គាល់ថាជា **សាឡុត បាន**) គាត់បានទទួលចម្លើយសារភាពរបស់ **កុយ ធួន** នាព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពី **សួង ស៊ីគឿន**។ ម្យ៉ាងវិញទៀត បើយោងទៅតាមសក្ខីកម្មរបស់សាក្សី នៅថ្ងៃទី៧ ខែសីហា **សាឡុត បាន** គឺជាអ្នកផ្តល់ចម្លើយសារភាពរបស់ **កុយ ធួន** ទៅគាត់។ **សួង ស៊ីគឿន** បានរក្សាជំហរថា ៖ "ខ្ញុំមិនដែលមានចម្លើយសារភាពអីទេព្រោះក្នុងឋានៈរបស់ខ្ញុំ ខ្ញុំមិនដែលបានទទួលចម្លើយសារភាពអីអីចឹងទេបាទ។ ដូច្នោះខ្ញុំមិនអាច គឺថាឲ្យចម្លើយសារភាពហ្នឹងទៅលោក **សួរ ហុង** បានទេ បាទ"។

មេធាវីក៏បានទាញចំណាប់អារម្មណ៍របស់ **សួង ស៊ីគឿន** ទៅលើសៀវភៅបោះពុម្ពផ្សាយមួយរបស់សាក្សីជំនាញ **ដេវីដ ឆេនដ៍ល័រ** (D108/50/1.75) ដែលមានអត្ថន័យដូចតទៅ ៖ "សមាជិក៣០នាក់របស់ **យូ.អ៊ិន.អ៊ី.ខេ** រួមទាំងកូនប្រុសរបស់**ទូច** ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ចូលប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៣ ក្រោយពេលពិនិត្យដោយជនជាតិកម្ពុជានៅប៉េកាំង"។ **សួង ស៊ីគឿន** បានអះអាងថា វាគ្មានដំណើរការពិនិត្យក្នុងស្ថានទូតប៉េកាំងទេដោយកត់សម្គាល់ថា "ឥឡូវលោកជឿ **ដេវីដ ឆេនដ៍ល័រ** ឬជឿខ្ញុំ? បើខ្ញុំនៅក្នុងហ្នឹងខ្ញុំជាអ្នករៀនសូត្រអីជាមួយពួកអស់ហ្នឹង"។ គាត់បានបន្ថែមថា "អត់មានជ្រើសរើសអីទេព្រោះពួកហ្នឹងមក -សុំមកប៉ុន្មានគេបញ្ជូនមកទាំងអស់ហ្នឹង ព្រោះពួកហ្នឹងសុទ្ធតែគេស្ម័គ្រចិត្តតើ"។

លើសពីនេះ **កាណាវ៉ាស** បានសួរសាក្សីឲ្យផ្តល់យោបល់ពីសក្ខីកម្មរបស់ **ឆេនដ៍ល័រ** នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១២ ទៅលើជីវប្រវត្តិដែល **ឆេនដ៍ល័រ** បាននិយាយដូចតទៅៈ "ខ្ញុំមិនគិតថា វាមានគោលបំណងអាក្រក់ក្នុងការស្នើសុំឲ្យសមាជិកនៃបុគ្គលិក**ស-២១** ឲ្យសរសេរជីវប្រវត្តិ--វាគឺជាការអនុវត្តន៍ជាទូទៅមួយ"។ ដោយមើលទៅហាក់ដូចជាមានគំនិតផ្ទុយនឹង **ឆេនដ៍ល័រ** សាក្សីបានគូសបញ្ជាក់ថា ជីវប្រវត្តិដែលគាត់បានសរសេរក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺ "ដោយកាលៈទេសៈពិសេស" ក្រោយពេលដែលខ្ញុំត្រូវបានចោទថាជាភ្នាក់ងារ **សេ.អ៊ី.អា**។[4]

### *ក.៣. ជំនួបរបស់ សួង ស៊ីគឿន ជាមួយសាក្សី វ៉ាចាម តន់*[5]

នៅទីបញ្ចប់នៃការសួរដេញដោលរបស់ **សួង ស៊ីគឿន** គាត់បានសារភាពថា គាត់បានជួបជាមួយ **វ៉ាចាម តន់** ជាសាក្សីដែលបានផ្ដល់សក្ខីកម្មពីថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា។ **សួង ស៊ីគឿន** បានថ្លែងថា គាត់បានសុំ **វ៉ាចាមតន់** នូវបទសម្ភាសន៍ថតចម្លងចុងក្រោយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី*ស្វែងរកការពិត*។ **វ៉ាចាម តន់** បានទៅផ្ទះ **សួង ស៊ីគឿន** នៅម៉ាឡៃ ហើយរថយន្តរបស់តុលាការបានទៅយក **វ៉ាចាមតន់** និងនាំគាត់មកកាន់ អ.វ.ត.ក ដើម្បីផ្ដល់សក្ខីកម្ម។ ពួកគាត់បានជួបគ្នាជាលើកទីពីរនៅ*សណ្ឋាគារមិត្តភាព* ជិតវត្តកោះតាមការស្នើសុំរបស់ **សួង ស៊ីគឿន**។ **សួង ស៊ីគឿន** បាននិយាយថា គាត់បានគិតថា **វ៉ាចាម តន់** មិនទាន់បានបញ្ចប់សក្ខីកម្មរបស់គាត់នៅឡើយទេ ពេលពួកគាត់ជួបគ្នា។ ពេលដែលត្រូវបានសួរពីគោលបំណងនៃជំនួបរបស់ពួកគាត់ **សួង ស៊ីគឿន** បាននិយាយថា គាត់ចង់សួរ **វ៉ាចាមតន់** ពីប្រភេទនៃសំណួរដែលបានសួរ ដូច្នេះគាត់ "អាចផ្ដល់សក្ខីកម្មពេញលេញនៅចំពោះមុខតុលាការ"។ ប៉ុន្តែមិនមានការបង្ហាញណាមួយរបស់ **វ៉ាចាម តន់** ឆ្លើយតបទៅនឹងសំណួររបស់ **សួង ស៊ីគឿន** ឡើយ។

### *ក.៤. អាកប្បកិរិយា និងភាពគួរឲ្យជឿទុកចិត្តរបស់សាក្សី*

បន្ទាប់ពីបានផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការអស់រយៈពេលបី ឬ បួនថ្ងៃក្នុងរយៈពេលបីសប្ដាហ៍ **សួង ស៊ីគឿន** បានឆ្លើយសំណួររបស់ **កាណាវ៉ាស** ដោយស្ម័គ្រចិត្ត និងមានទំនុកចិត្ត។ ប៉ុន្តែមានពេលខ្លះគាត់ហាក់ដូចជាច្រលំ ហើយមិនយល់ពីសំណួររបស់មេធាវីការពារក្ដី ជាពិសេសទាក់ទងទៅនឹងកាលបរិច្ឆេទ និងខ្លឹមសារនៃជីវប្រវត្តិ។ សុខភាពដ៏ទ្រុឌទ្រោមរបស់ **សួង ស៊ីគឿន** បានស្ដែងឲ្យឃើញនៅពេលដែលគាត់ជូនដំណឹងទៅអង្គជំនុំជម្រះថា គាត់ហត់ខ្លាំងក្នុងការបន្តសក្ខីកម្មកាលពីថ្ងៃចន្ទ។ យ៉ាងណាមិញ គាត់បានបន្តផ្ដល់សក្ខីកម្មនៅពេលរសៀល ដោយសារតែ **កាណាវ៉ាស** បានបញ្ជាក់ថា គាត់ត្រូវការតែពេលដប់នាទីទៀតប៉ុណ្ណោះដើម្បីបញ្ចប់ការសួរដេញដោលទៅកាន់សាក្សីរូបនេះ។

## ខ. សក្ខីកម្មរបស់សាក្សី ស សៀក

ចាប់ពីរសៀលថ្ងៃចន្ទដល់ព្រឹកថ្ងៃអង្គារ សាក្សី **ស សៀក** បានបន្តផ្ដល់សក្ខីកម្មរបស់អ្នកស្រីដែលបានធ្វើកាលពីសប្ដាហ៍មុន។[6] សាក្សីត្រូវបានសួរពីការងាររបស់គាត់ជាអ្នកចម្រៀងមួយរូបក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ការយល់ដឹងរបស់គាត់ទាក់ទងនឹងសេចក្ដីថ្លែងការណ៍របស់មេដឹកនាំ និងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលបានដាក់ឲ្យអនុវត្តក្នុងពេលនោះ។

### *ខ.១. ជីវប្រវត្តិផ្ទាល់ខ្លួនរបស់សាក្សី*

**ស សៀក** បានចូលរួមក្នុងចលនាបដិវត្តន៍ក្នុងឆ្នាំ១៩៧២ ពេលដែលអ្នកស្រីមានអាយុប្រហែល១៤ឆ្នាំ។ អ្នកស្រីបានបរិយាយថា អ្នកស្រីមិនបានចូលបដិវត្តន៍ដើម្បីហេតុផលនយោបាយទេ ប៉ុន្តែដោយសារតែអ្នកស្រីចង់ដុសខាត់ទេពកោសល្យរបស់គាត់ជាអ្នកចម្រៀងខ្មែរបុរាណ "អាយៃ"។ អ្នកស្រីបានពន្យល់ថា ទោះបីជា អ្នកស្រីបានដឹងតិចតួចពីបដិវត្តន៍ អ្នកស្រីបានចូលរួមក្រុមសម្ដែងសិល្បៈថ្នាក់ស្រុកតាមការ

អញ្ជើញរបស់មេភូមិ ក្រោយពីរដ្ឋប្រហាររបស់ **លន់ នល់**។ គាត់ជឿថា ក្រោយមកអ្នកស្រីត្រូវបានផ្ទេរទៅក្រុមសិល្បៈ "មជ្ឈិម" ដោយសារតែការណែនាំរបស់ **ទីវ អុល**[7] ជាអ្នកដែលបានឃើញការសម្តែងរបស់អ្នកស្រីនៅតំបន់២០ ។

### ខ.២. ការជម្លៀសចេញពីភ្នំពេញ

សាក្សីបានទទួលស្គាល់ថា ក្រោយ "ការរំដោះ" ទីក្រុងភ្នំពេញ អ្នកស្រីបានឃើញ **ខៀវ សំផន** ពេលក្រុមសិល្បៈរបស់លោកស្រីស្ថិតនៅលើភ្នំអដ្ឋរស្ស[8] ដើម្បីរង់ចាំចូលក្នុងរាជធានីតាមការបង្គាប់ពីថ្នាក់គ្រប់គ្រងរបស់ពួកគេគឺ លោក **ហូ នឹម** លោក **ទីវ អុល** និងលោក "**សៅ**"។ អ្នកស្រីកត់សម្គាល់ឃើញថា **ខៀវ សំផន** ដូចជាមានឫកពានឹងនរ និង "…គាត់មិនល្អល្ងាច ឬមួយក៏ក្រេវក្រោធនឹងជ័យជម្នះអីតែឯងនោះទេ"។ ពេលដែលមានការចោទសួរដោយចៅក្រម **ហ្សង់ម៉ាក ឡាវែន** ថាតើ **ខៀវ សំផន** ដូចជា "មានការប៉ះទង្គិចចិត្ត" **ស សៀក** បានឆ្លើយតបថា "នាងខ្ញុំមិនបានតាមដានឥរិយាបថ និងមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់គាត់ នាងខ្ញុំមិនបានយល់ទេ"។ អ្នកស្រីបានផ្តល់សក្ខីកម្មបន្ថែមថា អ្នកស្រីមិនអាចចាំបាននូវសុន្ទរកថាទាំងប្រាំមួយ[9] ដែលសំដៅទៅ **ខៀវ សំផន** ដែលបានផ្សព្វផ្សាយតាមរយៈ*សំឡេងរណសិរ្សរួបរួមជាតិ* ក្នុងអំឡុងពេលនៃការជម្លៀស។ អ្នកស្រីបាននិយាយដដែលៗថា អ្នកស្រីបានស្នាក់នៅពេញមួយយប់នៅស្ពាតអូឡាំពិក នៅពេលអ្នកស្រីមកដល់ទីក្រុងភ្នំពេញបីថ្ងៃក្រោយពីការរំដោះ។ អ្នកស្រីត្រូវបានគេផ្ទេរមកក្រសួងឃោសនាការនៅព្រឹកបន្ទាប់។ បើយោងទៅតាមសក្ខីកម្មរបស់ **ស សៀក** អ្នកស្រីគ្រាន់តែបានឃើញទាហានប្រុស និងមិនមានប្រជាជនស៊ីវិល ឬអ្នកស្នាក់នៅក្នុងទីក្រុងទេ។

### ខ.៣. ការងារនៅក្រសួងឃោសនាការ និងអប់រំ

បើយោងតាមសាក្សី ក្រសួងឃោសនាការ ក្រោយមក ត្រូវបានបញ្ចូលគ្នាជាមួយក្រសួងអប់រំ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **យុន យ៉ាត**។ នៅឯក្រសួង អ្នកស្រីបានធ្វើការក្នុងក្រុមសិល្បៈ ជាអ្នកចម្រៀងនៅក្នុងចន្លោះឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ហើយបានថតចម្រៀងសម្រាប់ការផ្សព្វផ្សាយតាមរយៈវិទ្យុ និងការសម្តែងផ្ទាល់។ បទចម្រៀងត្រូវបានសរសេរ និងផ្សាយដើម្បីលើកទឹកចិត្តមនុស្សឲ្យព្យាយាមធ្វើការ។ យោងតាមសក្ខីកម្មរបស់ **ស សៀក** មានតែក្រសួងទេ ដែលត្រូវបានជឿទុកចិត្តឲ្យថតបទចម្រៀងសម្រាប់ផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ។ បទចម្រៀងដែលបានថតមុនរបបកម្ពុជាប្រជាធិបតេយ្យ មិនត្រូវបានយកមកចាក់ផ្សាយទេ ពីព្រោះបទចម្រៀងទាំងនេះ "មិនស៊ីគ្នានឹងស្ថានការណ៍ពេលនោះ"។ អ្នកស្រីបានបញ្ជាក់ថាពីព្រោះគាត់មិនមានសមត្ថភាព គាត់មិនមែនជាអ្នកអានព័ត៌មាន ឬត្រូវបានឲ្យអានអត្ថបទ។

យោងតាមសក្ខីកម្មរបស់សាក្សី មេដឹកនាំជាន់ខ្ពស់មិនដែលទៅក្រសួង ដើម្បីផ្សាយពីសុន្ទរកថារបស់ពួកគាត់ទេ ផ្ទុយទៅវិញ សុន្ទរកថាត្រូវបានថតក្នុងខ្សែអាត់កាសែត ហើយប្រគល់ឲ្យទៅក្រុមវិទ្យុដើម្បីធ្វើការផ្សព្វផ្សាយ។ អ្នកស្រីមិនអាចចងចាំបានទេថា មេដឹកនាំរូបណាបានឲ្យសុន្ទរកថាដែលបានថតទុករួច និងមាតិកានៃសុន្ទរកថា ពីព្រោះអ្នកស្រីនិយាយថា អ្នកស្រីមិនបានផ្តោតអារម្មណ៍ទៅលើពួកគាត់។ លើសពីនេះទៀត អ្នកស្រីបានបដិសេធពីការស្តាប់ឮការផ្សព្វផ្សាយផ្សេងៗ នៃគោលនយោបាយខ្មែរម្នាក់សម្លាប់វៀតណាម ៣០នាក់។ **ស សៀក** បានសង្កត់ធ្ងន់ថា ការផ្សព្វផ្សាយវិទ្យុមុនការរំដោះ គឺនិយាយអំពីប្រជាជនដែលមិនមាន

អាហារគ្រប់គ្រាន់ និងត្រូវរស់នៅដោយមិនមានអ្វីៗជាប់ខ្លួនច្រើនឡើយក្រោយពីការរំដោះ កម្មវិធីវិទ្យុបានផ្តោតយ៉ាងសំខាន់លើការលើកទឹកចិត្តមនុស្សឲ្យជីកប្រឡាយ និងអាងស្តុកទឹក ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់វាលស្រែ។

ជាកិច្ចបន្ថែមពីនេះទៀត សាក្សីបានបង្ហាញថា គាត់ត្រូវបានប្តូរទៅមន្ទីរ ២៧ ក្នុងឆ្នាំ១៩៧៧ ដែលទទួលខុសត្រូវក្នុងការបោះពុម្ពសៀវភៅ។ អ្នកស្រីទទួលបន្ទុកធ្វើសៀវភៅរូបភាពក្នុងមន្ទីរ ២៧។

### *ខ.៤. ការអប់រំកែប្រែនៅជីក្រហម*

ក្នុងខែមេសា ឆ្នាំ១៩៧៨ **ស សៀក** និងកូនស្រីអាយុប្រាំបួនខែរបស់គាត់ ត្រូវបានគេយកទៅវត្តបុទមវត្តី ជាកន្លែងដែលពួកគាត់បានស្នាក់នៅចំនួនបីយប់។ ជាការពិត មិនមានវគ្គសិក្សាអប់រំត្រូវបានធ្វើឡើងនៅវត្តបុទមវត្តីឡើយ ហើយអ្នកស្រីត្រូវបានគេព្រមានមិនឲ្យដើរចេញបរិវេណនេះទេ។ បន្តិចក្រោយមក ពួកគាត់ត្រូវបានបញ្ជូនទៅកាន់តំបន់ជីក្រហម ដែលគាត់បានដឹងពីអ្នកបើកបររបស់ពួកគាត់ថា ជាកន្លែងដែលគាត់ត្រូវតែចូលសិក្សា "វគ្គឡើងវិញ"។ អ្នកស្រីបានចងចាំរឿងទុក្ខសោកពីព្រឹត្តិការណ៍នេះ ហើយនិយាយថា៖

> *"អ៊ីចឹងបងអត់អីទេបងទៅកសាងខ្លួនសាថ្មី។ បងកសាងខ្លួនហើយល្អបងនឹងបានចូលភ្នំពេញវិញ"។ ពេលនោះបានខ្ញុំដឹងថាខ្លួនខ្ញុំខុសអី។ ការពិតមកដល់សព្វថ្ងៃខ្ញុំមិនដឹងថាខ្ញុំខុសអីទេ។ ខ្ញុំព្រាត់ប្រាស់កូនព្រាត់ប្រាស់ប្តីម្តងហើយ។*

វាមិនមានភាពច្បាស់លាស់ទេថា ការអប់រំកែប្រែរបស់ **ស សៀក** នៅជីក្រហម បានធ្វើឡើងនៅកន្លែងណា ដោយសារតែប្រធានចៅក្រម **និល ណុន** បានរារាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី **បេនី យេ** មិនឲ្យបន្តបញ្ហានេះ ដោយហេតុថា វាមិនពាក់ព័ន្ធនឹងផ្នែកនៃដំណើរការកិច្ចនីតិវិធី។ (មើលផ្នែកទី៣.ឃ)

### *ខ.៥. ការបាត់ខ្លួន*

សាក្សីបានចងចាំថា មានបុគ្គលិកមួយចំនួនពីក្រសួងបានបាត់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមពួកគេមាន លោក **ហូ នឹម** លោក **ឆយ** ហៅ **"សៅ ចាន់"** (ជាអ្នកដែលជំនួស **ហូ នឹម**) សមមិត្ត **ហាន** ហៅ **"នុង ចេងលី"** ជាគ្រូតន្ត្រីមកពីក្រសួងឃោសនាការ លោក **សៅ** ហៅ **"តាយសឿង"** អ្នកទទួលបន្ទុកផ្នែកសិល្បះ ជំនួយការម្នាក់របស់ប្រធានផ្នែកសិល្បៈ និងអ្នកនិពន្ធ។ **ស សៀក** បានពន្យល់ថា គាត់មិនបានដឹងទេថា តើមនុស្សទាំងនេះត្រូវបានគេចាប់ខ្លួន ឬគ្រាន់តែត្រូវបានគេប្តូរ។ អ្នកស្រីបានបន្ថែមទៀតថា គាត់បានឮពីចម្លើយសារភាពរបស់មនុស្សដែលត្រូវបានគេចាត់ទុកថាជាជនក្បត់ រួមទាំងលោក **កុយ ធួន** និងមនុស្សម្នាក់ទៀតឈ្មោះ **ហុម សាមអរ** អ្នកដែលបានធ្វើអត្តឃាតនៅក្រសួង។

### ខ.៦. អាពាហ៍ពិពាហ៍នាសម័យកម្ពុជាប្រជាធិបតេយ្យ

បើយោងតាមសក្ខីកម្មរបស់ **ស សៀក** អ្នកស្រីបានរៀបការជាមួយស្វាមីទីមួយរបស់គាត់ ក្នុងឆ្នាំ ១៩៧៦។ អ្នកស្រីបានស្គាល់គាត់មុនពេលពួកគេរៀបការ ព្រោះគាត់បានធ្វើការផ្នែកផ្សព្វផ្សាយនៅក្រសួង។ **ស សៀក** បានពន្យល់ពីដំណើរការនៃការស្នើសុំរៀបការ ដូចតទៅ៖

> *"ចាសលោកស្រីពេលនោះមានការស្នើ--ចង់និយាយថា បើសិនបុរសណាស្រលាញ់នារីណាមួយ ស្នើសួរស្ដីដណ្ដឹងហ្នឹង ជាពាក្យសម្ដីតាមប្រធានដូចថាប្រធានខ្ញុំស្រីអីចឹងសួរមកហើយប្រធានស្រី ហ្នឹងយកយោបល់ហ្នឹងមកដើម្បីមកសាកសួរដក់សាមីខ្លួននាងខ្ញុំ។ ចាសបើនាងខ្ញុំព្រមហ្នឹងបាន ន័យថា សម្រេចទៅតាមគោលបំណងសេចក្ដីស្នើរបស់បុរសហ្នឹងហើយ"។*

អ្នកស្រីបានបន្ថែមថា អង្គការដូចជាឪពុករបស់ពួកគាត់៖ "ព្រោះអង្គការជាម៉ែជាឪចាស មិនមានម្ដាយឪពុកយើងពីស្រុកទេសអីណាមកជួយរៀបចំឲ្យទេ"។ ស្វាមីដំបូងរបស់អ្នកស្រីបាន "បាត់ខ្លួន" ឬ "ដកចេញ" នាសម័យកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ **ស សៀក** បាននិយាយថា "ខ្ញុំគ្មានដំណឹងពីគាត់ទេ។ ខ្ញុំមិនដឹងថាគាត់រស់ ឬស្លាប់ទេ"។ **ស សៀក** បានរៀបការឡើងវិញក្នុងឆ្នាំ១៩៨៣។

### ខ.៧. ទំនាក់ទំនងជាមួយជនជាប់ចោទ

លោកមេធាវី **កាណាវ៉ាស** បានសុំឲ្យអ្នកស្រី **ស សៀក** បកស្រាយលើការឆ្លើយតបរបស់អ្នកស្រីទៅកាន់សំណួររបស់ចៅក្រមស៊ើបអង្កេត ថាតើអ្នកស្រីបានឃើញ **ប៉ុល ពត** លោក **អៀង សារី** និង **នួន ជា** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាពិសេសពេលដែលអ្នកស្រីបានបង្ហាញថា "ពួកគាត់មិនដែលត្រូវបានឃើញ ប៉ុន្តែ **អៀង សារី** នៅក្រសួងការបរទេសនាពេលនោះ"។ **ស សៀក** បានបញ្ជាក់ថា គាត់មិនបានឃើញ **អៀង សារី** ទេនាពេលនោះ អ្នកស្រីគ្រាន់តែបានដឹងពីអ្នកផ្សេងថា គាត់ទទួលបន្ទុកក្រសួងការបរទេស។

សាក្សីបានសារភាពថា អ្នកស្រីបានឃើញ **ខៀវ សំផន** នាពេលផ្សេងគ្នា ប៉ុន្តែមិនមានអ្វីនៅក្នុងសក្ខីកម្មរបស់គាត់បង្ហាញថា អ្នកស្រីមានទំនាក់ទំនងដោយផ្ទាល់ជាមួយជនជាប់ចោទក្នុងរបបនេះទេ។[10] អ្នកស្រីមិនបានផ្ដល់សក្ខីកម្មទាក់ទងនឹងជនជាប់ចោទ **នួន ជា** ទេ។

### ខ.៨. ឥរិយាបថ និង ភាពគួរឲ្យជឿជាក់របស់សាក្សី

កាលពីសប្ដាហ៍មុន **ស សៀក** មានប្រតិកម្មអារម្មណ៍ អំឡុងពេលដែលអ្នកស្រីនិយាយពីគ្រួសារ និងបទពិសោធន៍របស់អ្នកស្រីនៅតំបន់ដីក្រហម។ អ្នកស្រីហាក់ដូចជាមានការចងចាំខ្សោយ ហើយប្រកាន់ជំហរថា អ្នកស្រីមិនចងចាំលម្អិតទេ ព្រោះអ្នកស្រីនៅក្មេងណាស់នាពេលនោះ មិនបានចាប់អារម្មណ៍ខ្លាំងទេទៅលើព្រឹត្តិការណ៍ដែលបានកំពុងកើតឡើង។ លើសពីនេះទៀត ក្រុមមេធាវីការពារក្ដីជនជាប់ចោទ **អៀង សារី** អាចបង្ហាញពីភាពផ្ទុយគ្នារវាងសក្ខីកម្មរបស់អ្នកស្រី និងសេចក្ដីថ្លែងការណ៍របស់ចៅក្រមស៊ើបសួរ ដូចជាថាតើអ្នកស្រីបានឃើញ **អៀង សារី** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ។ (មើលផ្នែកទី២.ខ.៧)

### គ. សក្ខីកម្មសាក្សី គឹម វុន

លោក **គឹម វុន** ហៅ "**ឆោម**" បានចាប់ផ្តើមផ្តល់សក្ខីកម្មកាលពីថ្ងៃអង្គារសប្តាហ៍នេះ ។[11] គាត់បានចូលរួមក្នុងចលនាបដិវត្តន៍ តាំងពីពេលដែលលោកនៅវ័យកុមារមកម្ល៉េះ និងថែមទាំងបានធ្វើការនៅតំបន់ផ្សេងៗគ្នាមួយចំនួនផងដែរ ក្នុងរោងពុម្ពផ្នែកកិច្ចការផ្សព្វផ្សាយរបស់បដិវត្តន៍ ។ តាមរយៈតួនាទីនេះ អាចឲ្យសាក្សីផ្តល់នូវព័ត៌មានស្តីពីការបោះពុម្ពផ្សាយនូវទស្សនាវដ្តី ឬឯកសារផ្សេងៗ ទាំងមុនពេល និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាទំនាក់ទំនងរបស់គាត់ជាមួយថ្នាក់ដឹកនាំនៃរបបនេះ ជាពិសេសលោក **ខៀវ សំផន** ។

#### *គ.១. ការងារនៅរោងពុម្ពកណ្តាល (១៩៧១-១៩៧៥)*

សាក្សី **គឹម វុន** បានបញ្ជាក់ថា គាត់បានចាប់ផ្តើមធ្វើការនៅរោងពុម្ពនៃរណសិរ្សរួបរួមជាតិកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ១៩៧១ តាំងពីគាត់ទើបតែមានអាយុ១០ ឆ្នាំមកម្ល៉េះ ។[12] សាក្សីបានពន្យល់ថា "នៅសម័យនោះ ក្មេងៗជាច្រើន ពិសេសបងប្អូនក្មួយខ្ញុំ គឺថាចូលមុនខ្ញុំទៅទៀត តែខ្ញុំរវល់ការងារនៅក្នុងភូមិខ្ញុំអត់បានចូលភ្លាមៗទេ" ។ ទោះបីជាសាក្សីហាក់នៅមានភាពស្ទាក់ស្ទើរក្នុងការចូលរួមជាមួយពួកគេក្តី ក៏គាត់ត្រូវបានគេបញ្ចុះបញ្ចូលឲ្យចូលជាមួយចលនាបដិវត្តន៍ និងបានធានាថា គាត់អាចធ្វើការនៅការិយាល័យមជ្ឈិមបក្ស ហើយក៏អាចត្រឡប់មកលេងស្រុកកំណើតផងដែរ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលគាត់បានចូលស៊ប់ គាត់ត្រូវបានគេណែនាំថា មិនត្រូវចាកចេញពីកន្លែងធ្វើការឡើយ ដើម្បីធានានូវគោលការណ៍រក្សាការសម្ងាត់ទាក់ទងនឹងការងារប្រចាំថ្ងៃរបស់គាត់ ហើយនិងរក្សាសន្តិសុខរបស់ពួកគេពីការវាយលុកតាមផ្លូវអាកាស និងការវាយប្រហារតាមទម្រង់ផ្សេងៗទៀត។ ខណៈដែលលោក **គឹម វុន** មិនមានជំនាញផ្នែកការងារបោះពុម្ពដូច្នេះ គាត់បានទទួលខុសត្រូវលើការងារការិយាល័យ និងមានភារៈជាអ្នកសរសេរអត្ថបទផ្សេងៗជាភាសាខ្មែរ ។

សាក្សីបានចង្អុលបង្ហាញថា រាល់ឯកសារដែលបោះពុម្ពចេញពីរោងពុម្ពនេះ ត្រូវបានយកទៅចែកចាយនៅតាមតំបន់រំដោះនានាតាមរយៈអ្នកនាំសារ (និរសារ) ។ ឯកសារទាំងនោះរួមមាន អត្ថបទព័ត៌មានស្តីពីសកម្មភាពនៅសមរភូមិ សេចក្តីថ្លែងការណ៍ដែលធ្វើដោយថ្នាក់ដឹកនាំ និងសារទូលេខដែលទាក់ទងនឹងការងារសមរភូមិមុខ ។ សាក្សីក៏បានបង្ហាញឲ្យដឹងផងដែរថា "កម្លាំងជំនួយរបស់ខ្មាំងជាច្រើនកងទៀត ត្រូវកម្ទេចឲ្យស្លាប់ របួស រត់ចោលជួរ និង ចាប់ជាឈ្លើយសឹក" ហើយព័ត៌មានទាំងនេះត្រូវបានផ្សាយតាមវិទ្យុ និងបោះពុម្ពជាទស្សនាវដ្តីមួយចំនួនរបស់បក្ស ។ លោក **គឹម វុន** បានបន្ថែមថា ព័ត៌មានស្តីពី "ស្ថិតិជាបឋមកម្លាំងរបស់ខ្មាំង១,៥៥០ ក្បាល ក្នុងនោះ រួមមាន: អាស័ក្តិ៥ អាស័ក្តិ៣ អាស័ក្តិ២ និងអាស័ក្តិ១ រាប់សិបក្បាលត្រូវយើងកម្ទេច និងមានប្រជាជនរាប់ម៉ឺននាក់ត្រូវបានរំដោះ" ត្រូវបានបោះពុម្ពផ្សាយដែរ ។ សាក្សីបានផ្តល់សក្ខីកម្មថា ថ្នាក់ដឹកនាំធំៗរបស់ខ្មែរក្រហម មិនដែលចុះមកការិយាល័យរោងពុម្ពឡើយ ដើម្បីណែនាំពីការចុះផ្សាយនូវសេចក្តីថ្លែងការណ៍របស់ពួកគាត់ ប៉ុន្តែមាននិរសារនាំយកសេចក្តីថ្លែងការណ៍ផ្សេងៗ មកឲ្យដល់ការិយាល័យរោងពុម្ព ។ សេចក្តីថ្លែងការណ៍ទាំងនេះ ត្រូវបានថតចម្លងទុក (ហ្វូតូកូពី) និងត្រូវបានបុគ្គលិកវិទ្យុអានក្នុងម៉ោងផ្សាយ។

សាក្សី **គឹម វុន** បានរម្លឹកឡើងវិញនូវសេចក្តីថ្លែងការណ៍ទទួលបានពីលោក **ខៀវ សំផន** ដែល "ច្រើនតែនិយាយជំរុញការវាយសម្រុកយកជ័យជម្នះនៅលើសមរភូមិ" ហើយនិងការអំពាវនាវឲ្យប្រជាជននៅតំបន់រំដោះ "ក៏ដូចជាកម្មាភិបាល យុទ្ធជន យុទ្ធនារីហ្នឹង ត្រូវជួយឧបត្ថម្ភគាំទ្រគ្នា ទាំងសមរភូមិមុខ និងសមរភូមិក្រោយ" ។ លើសពីនេះទៅទៀត សាក្សី **គឹម វុន** បានបញ្ជាក់អះអាងថា បានឃើញលោក **ខៀវ សំផន** នៅពេលដែលគាត់បានមកលេងនៅរោងពុម្ព ៖

> *ក្នុងសម័យនោះ ដោយសារខ្ញុំនៅក្មេង ខ្ញុំស្គាល់តែ បងហែម ដែលជាអ្នកចេញចូល កន្លែងនោះម្តងៗ ។ ឯក្រោយមកទៀត ទើបខ្ញុំដឹងថា បងហែម គឺ លោក ខៀវ សំផន ...ពេលនោះ បងហែម មកកន្លែងរោងពុម្ព ។ ជួនកាលគាត់មកសួរសុខទុក្ខអីចឹងទៅ មានយកបន្លែ ឬក៏ចំណីអីមកឲ្យក្មេងៗ និងឲ្យអ្នករោងពុម្ពហ្នឹងហូបខ្លះ ហើយលើកទឹកចិត្តអំពីការតស៊ូហ្នឹង។*

ដោយសារស្ថានីយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដំបូងឡើយមានទីស្នាក់ការនៅប្រទេសចិន រោងពុម្ពបានផ្ញើអត្ថបទព័ត៌មាននានាតាមរយៈសារទូរលេខដើម្បីចាក់ផ្សាយ ។ រាល់ខ្លឹមសារដែលទទួលបានពីសារទូរលេខ ត្រូវបានអ្នកអានព័ត៌មានយកទៅអាន និងថតសំឡេងទុក ហើយយកទៅចាក់ផ្សាយ ។ សាក្សី **គឹម វុន** បានបង្ហាញឲ្យដឹងថា "នៅឆ្នាំ១៩៧៣ ឆ្នាំ១៩៧៤ កៀកឆ្នាំ១៩៧៥ មានបង្កើតវិទ្យុរណសិរ្សនៅទីក្រុងភ្នំពេញនៅមន្ទីរ ប-២០ ។ ដូច្នេះ វិទ្យុផ្សាយសំឡេងហ្នឹងនៅជិតរោងពុម្ពខ្ញុំដែរ" ។ សាក្សី **គឹម វុន** បានផ្តល់សក្ខីកម្មថា រោងពុម្ពមជ្ឈិមបានប្តូរទីតាំងចំនួនបីដងក្នុងរយៈពេលតែពីរ ឬបីឆ្នាំ ។ ដំបូងទី រោងពុម្ពនេះមានទីតាំងនៅក្នុងព្រៃ តាមបណ្តោយដងស្ទឹងជិតនៃស្រុកសន្ទុក ដែលទីតាំងនេះ មានចម្ងាយឆ្ងាយពីផ្ទះរបស់ **ប៉ុល ពត** ប្រមាណជាពីរ ឬបីគីឡូម៉ែត្រ ។ ក្រោយមកទៀត វាត្រូវបានប្តូរទៅកាន់មន្ទីរ ២៤ ហើយតពីនេះ ក៏បានប្តូរទៅមន្ទីរ ប-២០ ក្នុងស្រុកស្ទឹងត្រង់វិញ ។

## *គ.២. ក្រសួងឃោសនាការ និងអប់រំ (១៩៧៥-១៩៧៩)*

យោងតាមសាក្សី **គឹម វុន** ក្រសួងឃោសនាការ និងអប់រំ បានទទួលមើលការខុសត្រូវមន្ទីរមួយចំនួន រួមមានមន្ទីរ ក-២៥ រហូតដល់មន្ទីរ ក-៣១ ។ មន្ទីរ ក-២៥ គឺជាការិយាល័យរបស់រដ្ឋមន្ត្រី និងក៏ជាកន្លែងដែលផ្នែកមួយចំនួននៃ *ទស្សនាវដ្តីទង់បដិវត្តន៍* និង *ទស្សនាវដ្តីយុវជនបដិវត្តន៍* ត្រូវបានគេបោះពុម្ពចេញពីទីតាំងមួយនេះ។ ចំណែកឯគម្របនៃទស្សនាវដ្តីវិញ ត្រូវបានគេបោះពុម្ពនៅមន្ទីរ ក-៦។ ដោយឡែក រាល់ឯកសារជាភាសាបរទេស ត្រូវបានបោះពុម្ពនៅមន្ទីរ ក-២៧។ លោកស្រី **យុន យ៉ាត** បានក្លាយជារដ្ឋមន្ត្រីនៃក្រសួងឃោសនាការ និងអប់រំ បន្ទាប់ពីការបាត់ខ្លួនកម្មាភិបាល **ហ៊ូ នឹម** ក្នុងឆ្នាំ១៩៧៧ ឬ១៩៧៨ ។ លោកស្រីបានកាន់តួនាទីមួយនេះ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ សាក្សី **គឹម វុន** បានផ្តល់សក្ខីកម្មថា បើទោះជាលោក **នួន ជា** មិនមានឋានៈជាអ្នកដឹកនាំនៅក្នុងក្រសួងក៏ដោយ ក៏គាត់មានអំណាចចាត់ចែងការងារផ្នែករដ្ឋបាលដោយផ្ទាល់ជាប្រចាំថ្ងៃនៅពេលដែលលោកស្រី **យុន យ៉ាត** អវត្តមានម្តងៗ។ លើសពីនេះទៅទៀត សាក្សីបាននិយាយថា គាត់បានដឹងថា ជនជាប់ចោទរូបនេះទទួលបន្ទុកលើកម្មវិធីអប់រំផ្នែកកសិកម្ម។

សាក្សី **គឹម វុន** និងបុគ្គលិកផ្សេងទៀតដែលធ្វើការនៅមន្ទីរ ប-២០ ត្រូវបានគេបញ្ជូនទៅទីក្រុងភ្នំពេញក្រោយពីការ "រំដោះ"។ សាក្សីបាននិយាយថា គាត់បានមកដល់កណ្តាលក្រុងភ្នំពេញ នៅថ្ងៃទី១៨ ខែមេសា ហើយទីតាំងដែលគាត់បានធ្វើការកាលនោះ គឺនៅក្នុងអតីតការិយាល័យ *កាសែតសង្គ្រោះជាតិ* ទល់

មុខស្ពាតអូឡាំពិក នៅជាប់នឹងអតីតក្លឹបប្រដាល់ *ស៊ីជូ* ។ សាក្សីបានចង្អុលបង្ហាញថា ដើមឡើយ គាត់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរ ក-២៥ ដែលនៅទីនោះ មុខងាររបស់គាត់គឺជាជំនួយការផ្នែកផលិត កម្មទស្សនាវដ្តី និងកាសែត ដោយមាននាទីជាអ្នកសរសេរចំណងជើងនឹងដៃ ។ បន្ទាប់មកទៀត លោកស្រី **យុន យ៉ាត** បានបញ្ជូនគាត់ឲ្យទៅធ្វើការនៅផ្នែកផ្សេងមួយទៀត និងបានតែងតាំងគាត់ឲ្យក្លាយទៅជាអ្នកថតរូប និងជាអ្នកនិពន្ធអត្ថបទសម្រាប់ *កាសែតបដិវត្តន៍* ។ ខ្លឹមសារនៃចំណងជើងទស្សនាវដ្តី និងកាសែតដែលគាត់បានដាក់កាលនោះ ត្រូវបានរួមគ្នាសម្រេចនៅក្នុងអង្គប្រជុំជាមួយអ្នកនិពន្ធមួយចំនួនទៀត ក្រោមការដឹកនាំរបស់លោកស្រី **យុន យ៉ាត** ។ ប្រធានបទចម្បងដែលត្រូវបានសម្រេចឲ្យសរសេរដាក់ក្នុង*កាសែតបដិវត្តន៍* គឺខ្លឹមសារទាំងឡាយណាដែលនិយាយពីការកសាង និងការការពារប្រទេស រួមជាមួយនឹងការលើកទឹកចិត្តឲ្យមហាជនខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធនានា ផ្សាភ្ជាប់នឹងការជំរុញឲ្យបង្កបង្កើនការធ្វើកសិកម្មផងដែរ តាមរយៈអត្ថបទចុះផ្សាយទាំងនោះ។ លោក **គឹម វុន** បានធ្វើការកត់សម្គាល់ថា ច្បាប់ចម្លងនៃកាសែតចុះផ្សាយទាំងឡាយ ត្រូវបានចែកចាយទៅតាមមូលដ្ឋាននៅទូទាំងប្រទេស ប៉ុន្តែសាក្សីមិនច្បាស់ថាតើអត្ថបទទាំងនោះ បានធ្លាក់ដល់ដៃប្រជាជនដែរ ឬយ៉ាងណានោះទេ ។ សាក្សីបានបន្ថែមឲ្យដឹងថា "សារព័ត៌មានគឺជាមធ្យោបាយដើម្បីផ្សព្វផ្សាយនូវសារ ឬក៏ព័ត៌មានអំពីទស្សនាវដ្តីទង់បដិវត្តន៍ផ្សព្វផ្សាយទៅមហាជន" ។

សាក្សីបានពន្យល់ថា គាត់ត្រូវតែសុំការអនុញ្ញាតទៅកាន់ក្រសួងពាក់ព័ន្ធនានា មុនពេលគាត់អាចទៅប្រមូលយកព័ត៌មាន ចុះទៅថតរូបនៅតាមអង្គភាព និងតំបន់ផ្សេងៗ ។ គាត់បានបង្ហាញឲ្យដឹងថា ដោយសារតែមេដឹកនាំផ្ទាល់របស់គាត់ គ្រាន់តែចាត់តាំងឲ្យគាត់ចុះទៅធ្វើការយកព័ត៌មានតែពីកន្លែងណាដែលប្រជាជនមើលទៅមានសុខភាពល្អ មានហូបចុកគ្រប់គ្រាន់ ដូច្នេះ គាត់ក៏មិនបានដឹងពីស្ថានភាពអត់ឃ្លាន ឬក៏ឃើញស្ថានភាពប្រជាជនធ្វើការហួសកម្លាំងដែរ នៅក្នុងអំឡុងពេលដែលគាត់ត្រូវធ្វើដំណើរចុះទៅតាមបណ្តាខេត្តមួយចំនួនទៅយកព័ត៌មាន។ នៅទីក្រុងភ្នំពេញឯណោះវិញ សាក្សីបានកត់សម្គាល់ថា មិនមានបញ្ហាខ្វះខាតស្បៀងអាហារឡើយ ។ ទោះជាយ៉ាងណាក្តី នៅតំបន់២៥ គឺជាទីតាំងដែលមានប្រជាជនរស់នៅច្រើន ពោលគឺមាន "ប្រជាជនថ្មី" ជាច្រើន ដែលអ្នកទាំងនេះសុទ្ធតែត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយប្រជាជនទាំងនោះ សុទ្ធតែជួបបញ្ហាខ្វះខាតស្បៀងអាហារ ។

នៅក្នុងឆ្នាំ១៩៧៧ សាក្សីត្រូវបានគេបញ្ជូនទៅធ្វើការនៅក្នុង*ស្ថានីយវិទ្យុកម្ពុជាក្រោម* នៃក្រសួងឃោសនាការ និងអប់រំ ។ គាត់ក៏ត្រូវបានទទួលការតែងតាំងជាប្រធាននៃស្ថានីយវិទ្យុមួយនេះបានរយៈពេលមួយឆ្នាំ ។ បើយោងតាមការបកស្រាយបន្ថែមរបស់ **គឹម វុន** ស្ថានីយវិទ្យុបានចាក់ផ្សាយនូវចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ដែលបានទទួលព័ត៌មានដូចតទៅ ៖

> *ព័ត៌មានដែលទទួលបាន (ព័ត៌មាន) ពីរប្រភេទ ។ ទី១ ប្រភពដែលយកព័ត៌មានពី ព្រំដែន។ ទី២ យើងសរសេរបំបែកប្រភពតាមព័ត៌មានចេញពីចម្លើយរបស់ឈ្លើយសឹក វៀតណាម ព្រោះឈ្លើយសឹកវៀតណាម និងខ្មែរក្រោម បើយើងគិតជាភូមិសាស្ត្រ គឺនៅក្នុងទឹកដីរបស់គេ ។...ដូច្នេះ បើចង់បានទទួលព័ត៌មានពិត ចង់ដឹងភូមិសាស្ត្រ យើងជួបនឹងខ្មែរក្រោមដែលភៀសខ្លួនមកពីព្រំដែនមកស្រុកខ្មែរយើងពេលដែលមានកើតវឹកវរនៅយួនខាងត្បូង ។*

## គ.៣. *ទស្សនាវដ្ដីនានារបស់បដិវត្តន៍*

សាក្សី **គឹម វុន** បានបំភ្លឺឲ្យដឹងថា ដំបូងឡើយ *ទស្សនាវដ្ដីទង់បដិវត្តន៍* ត្រូវបានបោះពុម្ពនៅដើមឆ្នាំ ១៩៧០ និងថាការបោះពុម្ពពេលនោះ គឺគ្រាន់តែជា "ឯកសារផ្ទៃក្នុងរបស់បក្ស" តែប៉ុណ្ណោះ ប្រើសម្រាប់ជាព័ត៌មានក្នុងវគ្គបណ្ដុះបណ្ដាលដល់កម្មាភិបាល ។ រាល់ច្បាប់ចតចម្លងនៃទស្សនាវដ្ដី ត្រូវបានគេដាក់នៅក្នុងឡានមួយចំនួន និងបានបញ្ជូនយកទៅតាមតំបន់ និងភូមិភាគនានា ។

តាមគាត់ដឹង ទស្សនាវដ្ដីទាំងនេះ មិនត្រូវបានចែកចាយទៅឲ្យបុគ្គលឯកជនណាមួយឡើយ ប៉ុន្តែបានចែកចាយយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ក្រុមកម្មាភិបាល ។ ដំបូងឡើយ គម្របនៃទស្សនាវដ្ដីមានឃើញតែរូបទង់ជាតិមួយទេ តែក្រោយមកទៀត បានកែប្រែទៅជាមានទង់ចំនួនប្រាំ ។[13]

ខណៈដែលគាត់មិនអាចគូសបញ្ជាក់បាន ថានរណាជាអ្នកសរសេរអត្ថបទសម្រាប់ទស្សនាវដ្ដីទង់បដិវត្តន៍ សាក្សីបានចង្អុលបង្ហាញថា រាល់ព័ត៌មានដែលមាននៅក្នុងទស្សនាវដ្ដី គឺបានពីថ្នាក់ដឹកនាំ ។ ដើម្បីគាំទ្រដល់ការអះអាងនេះ សាក្សីបានចង្អុលបង្ហាញថា **ប៉ុល ពត** ជាអ្នកដែលបានចារនូវចំណារមួយចំនួននៅបរិវេណអត្ថបទទាំងនោះ មុនពេលផ្ញើចេញទៅផ្នែករោងពុម្ពឲ្យរៀបចំបោះពុម្ព ។ ដូចគ្នានឹងកាសែតបដិវត្តន៍ដែរ ទស្សនាវដ្ដីទង់បដិវត្តន៍ ផ្ដោតសំខាន់ទៅលើមនោគមន៍វិជ្ជានយោបាយ ព្រមទាំងសារសំខាន់ៗស្ដីពីកិច្ចការពារ និងការកសាងប្រទេសជាតិឡើងវិញ ។ សាក្សីបានចង្អុលបង្ហាញថា មានការចុះផ្សាយទស្សនាវដ្ដីក្នុងលេខមួយ ដែលបានដាក់បញ្ចូលនូវចម្លើយសារភាពរបស់លោក **កុយ ធួន** ជាពេលដែលសាក្សីបានដឹងថាមានការចាប់ខ្លួនថ្នាក់ដឹកនាំធំៗរបស់កម្ពុជាប្រជាធិបតេយ្យ ។ ទោះជាយ៉ាងនេះក្ដី សាក្សី **គឹម វុន** បានគូសបញ្ជាក់ថា គាត់បានដឹងព្យឿងនេះ ចាប់តាំងពីពេលដែលគាត់ត្រូវបានគេចាត់តាំងឲ្យទៅធ្វើការជាអ្នកសរសេរអត្ថបទកាសែត គាត់ "មិនដឹងពីរចនាសម្ព័ន្ធសម័យនោះយ៉ាងម៉េច...ពាក់ព័ន្ធនឹងការដឹកនាំក្នុងក្រសួងផ្សេងទៀតក៏ខ្ញុំអត់ដឹង" ហើយក៏មិនយល់ ពីនយោបាយនៅពីក្រោយទស្សនាវដ្ដីទង់បដិវត្តន៍នោះយ៉ាងណាដែរ ដូច្នេះ គាត់ក៏មិនអាចផ្ដល់យោបល់បានដែរ ។

ស្រដៀងគ្នានេះផងដែរ យោងតាមសាក្សីបានឲ្យដឹងថា ការបោះពុម្ពផ្សាយនៃទស្សនាវដ្ដីទង់យុវជនយុវនារីបដិវត្តន៍ បានចាប់ផ្ដើមនៅអំឡុងដើមឆ្នាំ១៩៧០ ។ អ្នកអានទស្សនាវដ្ដីយុវជនយុវនារីបដិវត្តន៍ គឺជាសម្ព័ន្ធយុវជនដែលសាក្សី **គឹម វុន** បានអធិប្បាយថា "សម្ព័ន្ធយុវជនកុម្មុយនីស្ដកម្ពុជា គឺជាដៃស្ដាំរបស់បក្ស"។ សាក្សីបានថ្លែងថា លោកស្រី **យុន យ៉ាត** គឺជាអ្នកសរសេរអត្ថបទផ្សេងៗ សម្រាប់ទស្សនាវដ្ដីទង់បដិវត្តន៍យុវជន ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## គ.៥. *វគ្គសិក្សារៀនសូត្រ ខ្វាំង និងការបាត់ខ្លួន*

អំឡុងពេលធ្វើការនៅមន្ទីរ ប-២០ សាក្សី **គឹម វុន** បានចូលរួមក្នុងវគ្គសិក្សារៀនសូត្រមួយចំនួនដែលការប្រជុំទាំងនោះផ្ដោតសំខាន់លើសារៈសំខាន់នៃការរក្សានូវសាមគ្គីភាព ការរក្សាការសម្ងាត់ និងការខិតខំប្រឹងប្រែងធ្វើការងារដើម្បីទទួលបានជ័យជម្នះពីសង្គ្រាម ។ សាក្សីបានរម្លឹកថា លោកស្រី **យុន យ៉ាត** ជាអ្នកដឹកនាំនូវវគ្គសិក្សារៀនសូត្រនៅឯមន្ទីរ ប-២០ ព្រមទាំងនៅមន្ទីរឃោសនាការ និងអប់រំផងដែរ ។ សាក្សីក៏បានកត់សម្គាល់ផងដែរថា **ប៉ុល ពត** បានដឹកនាំក្នុងវគ្គសិក្សារៀនសូត្រមួយចំនួននៅក្នុងឆ្នាំ១៩៧៦ ។ តាម

ពិតទៅ រាល់ការពាក់ព័ន្ធទាំងអស់របស់គាត់ជាមួយនឹងបក្ស ដោយមិនគិតពីទីតាំងនៃកន្លែងធ្វើការ វគ្គបំពាក់បំប៉នផ្នែកទ្រឹស្ដីនយោបាយក៏ត្រូវបានធ្វើឡើងផងដែរ ។ វគ្គរៀនសូត្រទាំងនេះ មានបំណងក្នុងការបណ្ដុះបណ្ដាលកម្មាភិបាលទាំងឡាយ ឲ្យអនុវត្តមុខងារតាមជំនាញរៀងៗខ្លួន និងដើម្បីធានាថាគ្រប់គ្នាបំពេញមុខងារបានល្អប្រសើរពោលគឺ ខ្លឹមសារសំខាន់ៗ គឺថា នៅក្នុង "សម័យសង្គ្រាម គឺណែនាំអំពីការធ្វើសង្គ្រាម... ប៉ុន្តែនៅក្នុងពេលសន្តិភាព គឺមានការពារប្រទេស និងកសាងប្រទេស" ។

ក្រោយពី "រំដោះ" បានទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ វគ្គសិក្សារៀនសូត្រត្រូវបាន ធ្វើឡើងនៅក្នុងបូរីកីឡា ។[14] សម្រាប់វគ្គបំពាក់បំប៉នដល់កម្មាភិបាលជាថ្នាក់ដឹកនាំ ជាទូទៅមានរយៈពេលប្រមាណជាពីរ ឬបីខែ ចំណែកវគ្គបំពាក់បំប៉នសម្រាប់កម្មាភិបាលថ្នាក់ក្រោមវិញ គឺត្រូវបានធ្វើឡើងក្នុងរយៈពេលពីមួយ ឬពីរសប្ដាហ៍ ។ សាក្សីបានបន្ថែមបង្ហាញឲ្យដឹងទៀតថា ក្នុងពេលប្រជុំ គឺមានការជជែកផងដែរអំពីខ្មាំងផ្ទៃក្នុង និង ខ្មាំងខាងក្រៅ ៖ វៀតណាម (យួន) ពួក **កា.ហ្សេ.ប៊េ** ពួក **ស៊ី.អាយ.អេ** ត្រូវបានគេកំណត់គោលដៅស្វែងរក ។ សាក្សី **គឹម វុន** បានសង្កត់ធ្ងន់ថា វាមានការពិបាកនឹងកំណត់ថានរណាជាមិត្ត ហើយនរណាជាសត្រូវ ៖

> *ក្រោយពីមានព្រឹត្តិការណ៍ដែលថាវិកវរផ្ទៃក្នុងអីចឹងទៅ ថ្នាក់ដឹកនាំក៏ដូចជាខ្លួនខ្ញុំដែរ អត់មានអារម្មណ៍ថាត្រូវដើរទេ (ដើរយកព័ត៌មាន) ព្រោះបើដើរខ្លាចមានគ្រោះថ្នាក់ ព្រោះតែមានការបែងចែកគ្នា សូម្បីតែពីក្នុងភាគីតែមួយ ដែលបែកចំពាមទៅច្រើន អីចឹង វាពិបាកណាស់ មិនដឹងថានរណាខ្មាំង មិនដឹងថានរណាជាមិត្ត ។ និយាយរួមគឺថា បើនិយាយប្រៀបធៀបនឹងទឹកវិញ នៅសម័យនោះ គឺថាទឹកហ្នឹងបានល្អក់អស់ទៅហើយ ព្រោះមានអ្នកបានកកូកកាយឲ្យល្អក់អស់ទៅហើយ ។ នៅក្នុងទឹកហ្នឹង វាមិនឃើញកំពិស ឃើញក្ដាម ឃើញត្រីតូចត្រីធំអីយ៉ាងម៉េចគឺអត់ទេ មើលមិនឃើញទេ ហើយនៅក្នុងអារម្មណ៍របស់ខ្លួន គឺភ័យខ្លាចរហូតដែរ ។*

យោងតាមសាក្សី **គឹម វុន** បានឲ្យដឹងថា បន្ទាប់ពីបាត់ខ្លួនប្រពន្ធរបស់គាត់មក គឺអ្នកស្រី **ជឹម ឈាណារី** ហៅ "**ភណ្ឌ**" ក្នុងឆ្នាំ១៩៧៧ រូបគាត់ត្រូវបានគេតម្រូវឲ្យទៅចូលរួមក្នុងវគ្គសិក្សារៀនសូត្ររយៈពេលកន្លះខែ ដើម្បី "រៀបចំខ្លួនកសាងប្រទេស" និងដើម្បីប្រយុទ្ធប្រឆាំងនឹងខ្មាំងដែលបង្កប់ក្នុងខ្លួន ហេតុដូច្នេះហើយ "ត្រូវមានការប្រុងប្រយ័ត្ន" ។ បន្ទាប់ពីនេះមក សាក្សីត្រូវបានគេប្ដូរឲ្យទៅធ្វើការនៅក្នុងស្ថានីយវិទ្យុកម្ពុជាក្រោម (*សូមមើលផ្នែកទី២.គ.២*) ។

## *គ.៦. អត្តចរិត និងភាពជឿជាក់ចំពោះសាក្សី*

សេចក្ដីថ្លែងការណ៍របស់លោក **គឹម វុន** កន្លងទៅមានភាពស៊ីចង្វាក់គ្នាជាហូរហែ ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់គាត់ ។ សាក្សីត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតបនឹងសំណួរទាំងឡាយពីសំណាក់ភាគីទាំងអស់ និងបានជូនដំណឹងដោយភាពស្មោះ ទៅកាន់ភាគីម្ចាស់សំណួរ នៅរាល់ពេលដែលមានសំណួរណាមួយនោះ ក្រៅពីវិសាលភាពនៃការដឹងឮរបស់គាត់ ។ សាក្សីបានបង្ហាញពីការខិតខំព្យាយាមក្នុងការផ្ដល់សក្ខីកម្មរបស់គាត់ ថ្វីបើសាក្សីប្រែជាមានអារម្មណ៍សោកសង្រេងខ្លះៗ នៅពេលជជែកដល់ការបាត់ខ្លួនប្រពន្ធរបស់គាត់ និងបទពិសោធន៍ជូរចត់ នៅពេលដែលគាត់ត្រូវបែកចេញពីម្ដាយ ។

ក្នុងអំឡុងដែលសាក្សីរូបនេះ ត្រូវបានសួរដេញដោលមេធាវីការពារក្ដី គឺលោក **កាណាវាស** កាលពីថ្ងៃព្រហស្បតិ៍ សាក្សី **គឹម វុន** បានប្រកាសថា តាំងពីគាត់ជាប់មានធុរៈផ្ទាល់ខ្លួន នៅពេលដែលបុគ្គលិក មកពី

ការិយាល័យសហចៅក្រមស៊ើបអង្កេតចុះទៅជួបគាត់ ដើម្បីធ្វើការសម្ភាសន៍ជាលើកទីបី គាត់ក៏បានស្នើទៅពួកគេឲ្យនៅរង់ចាំគាត់សិន ។ ទោះជាយ៉ាងនេះក្តី សាក្សីបានរម្លឹកការចងចាំរបស់គាត់ថា មន្ត្រីស៊ើបអង្កេត "គាត់អត់រង់ចាំគាត់ចេញដំណើរទៅ"។ ឆ្លើយតបនឹងការលើកឡើងនេះ មេធាវីការពារក្តី **កាណាវ៉ាស** បានយោងទៅលើដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺលោក **ម៉ាកសែល ឡឺម៉ុងដ៍** បានចេញសេចក្តីថ្លែងការណ៍ថា នៅខែតុលា ឆ្នាំ២០០៩ "សហចៅក្រមស៊ើបអង្កេតបានជួបលោក **គឹម វុន** ប្រយោជន៍ដើម្បីស្តាប់ចម្លើយគាត់ជាលើកទីបី ដើម្បីវិភាគបញ្ហាដែល លើកឡើងក្នុងសំណើរបស់សហព្រះរាជអាជ្ញា ប៉ុន្តែ *...មកដល់ដំណាក់កាលនេះ ស្រាប់តែសាក្សីរូបនេះលែងសហការណ៍ទាំងស្រុង ហើយបដិសេធដាច់អហង្ការមិនឲ្យសម្ភាសគាត់តទៅទៀតទេ*" ។ សាក្សី **គឹម វុន** បានពន្យល់តបទៅមេធាវីយ៉ាងដូច្នេះថា:

> *ហេតុការណ៍ដូចខ្ញុំបានលើកឡើងហើយ បើគាត់សហការណ៍នឹងខ្ញុំមានវិធីស្រួលបួលប្រកបដោយសីលធ៌ម អត់អីទេ ។ ប៉ុន្តែវិជ្ជាជីវៈបែបហ្នឹងខ្ញុំទទួលយកវាអត់បាន បើគាត់ប្រើពាក្យអសុរោះអីចឹង ។ គាត់ថាខ្ញុំមិនសហការណ៍ គឺនិយាយហ្នឹងអត់ទទួលខុសត្រូវ ព្រោះគាត់ជាមន្ត្រីការងាររបស់រដ្ឋាភិបាល ការងារសហប្រជាជាតិប៉ុណ្ណាណី ...នៅក្នុងតុលាការហ្នឹង មានទាំងខ្មែរ មានបរទេស ។ អីចឹង សូមឲ្យលោកខាងខ្មែរហ្នឹង ខំសួរឲ្យបានច្រើនទៅ កុំចាំតែបកប្រែតាមគេ...ហើយខ្ញុំមានអំណាចអី មានសិទ្ធិអី ប្រឆាំងនឹងតុលាការ ដែលមានខ្មែរ និងបរទេសរួមគ្នាបង្កើតឡើងបានដល់ថ្ងៃនេះ ។*

## ឃ. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន

សប្តាហ៍នេះ អង្គជំនុំជម្រះ បានស្តាប់សក្ខីកម្មរបស់លោក **អែម អឿន** ហៅ "**យ៉ឹប លន**"[15] ជាដើមបណ្តឹងរដ្ឋប្បវេណីទីបីហើយ ដែលបានចូលខ្លួនមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ ។ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមសួរដេញដោលទៅកាន់លោក **អែម អឿន** មុនគេ ដោយជាបឋមបានផ្តោតទៅលើប្រធានបទស្តីពីបទពិសោធន៍នានាក្នុងនាមជាគ្រូពេទ្យ មុនពេល និងក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាគោលនយោបាយមួយចំនួន ដែលត្រូវបានអនុវត្តដោយរបបនេះ ។

### *ឃ.១. ជីវប្រវត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន*

យោងតាមលោក **អែម អឿន** បានឲ្យដឹងថា គាត់មានប្រភពពីក្រុមគ្រួសារក្រីក្រមួយ និងមិនធ្លាប់ដែលបានចូលសាលារៀនសូត្រតាមផ្លូវការណាមួយឡើយ ។ គាត់បានរម្លឹកឡើងវិញថា ឪពុករបស់គាត់មានតួនាទីសំខាន់នៅក្នុងចលនាអ៊ីសារ៉ាក់ (ចលនាប្រឆាំងនឹងបារាំង) ។ នៅពេលដែលគាត់ទើបមានអាយុប្រមាណជា១០ ឆ្នាំ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានទៅទីក្រុងភ្នំពេញ ដើម្បីទៅធ្វើការជាក្មេងបម្រើ ឬហៅថា "កូនគូលី" នៅផ្ទះឪពុកមារបស់គាត់ ។ គាត់បានស្នាក់នៅជាមួយឪពុកមារបស់គាត់ដែលជាវេជ្ជបណ្ឌិតមួយរូប ហើយតាមរយៈការស្នាក់នៅក្នុងអំឡុងពេលនោះហើយ ដែលធ្វើឲ្យគាត់មានឱកាសរៀនសូត្រនូវវិជ្ជាពេទ្យ ។ លោក **អែម អឿន** បានមានប្រសាសន៍ថា ឪពុកមារបស់គាត់ បានអនុញ្ញាតឲ្យគាត់ត្រឡប់ទៅផ្ទះជួបឪពុកម្តាយវិញ មុនពេលដែលខ្មែរក្រហមជិតគ្រប់គ្រងប្រទេសបានទាំងស្រុង ។

## *ឃ.២. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន មុនឆ្នាំ ១៩៧៥*

តាមដឹងមកថា ខ្មែរក្រហមបានជ្រើសតាំងលោក **អែម អឿន** ឲ្យធ្វើការនៅពេលដែលពួកគេ បានដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺជាកូនប្រុសនៃក្រុមគ្រួសារមួយ ដែលមានចំណេះដឹងខាងវិជ្ជាពេទ្យ ។ នៅពេលដែលគាត់មានអាយុ២០ឆ្នាំ គាត់ត្រូវបានគេអនុញ្ញាតឲ្យទៅទទួលវគ្គបណ្តុះបណ្តាលបន្ថែមនៅឯប្រទេសវៀតណាម ដែលទទួលបានការអនុញ្ញាតដោយផ្ទាល់ពីលោក **សោ ភឹម** ជាលេខាធិការនៃភូមិភាគបូព៌ា ។ តពីនេះមក ឪពុករបស់លោក **អែម អឿន** លោក **សោ ភឹម** ព្រមទាំងកម្មាភិបាលមួយរូបផ្សេងទៀតឈ្មោះ **ខុម** បានស្នើសុំឲ្យលោក **អែម អឿន** បម្រើការងារក្នុងនាមជាវេជ្ជបណ្ឌិតមួយរូប[16] នៅតំបន់២០[17] ដោយស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីសមមិត្ត **ខុម** ។ ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងថា ពេលនោះគាត់មានមុខងារក្នុងការផ្តល់វគ្គបណ្តុះបណ្តាលលើមូលហេតុ និងវិធីព្យាបាលជម្ងឺមួយចំនួន ។ គាត់បានអត្ថាធិប្បាយនូវភារកិច្ចរបស់គាត់ដូចខាងក្រោមនេះ ៖

> *នៅកន្លែងរបស់ខ្ញុំផ្ទាល់ ក្រោយពីពេលដែលខ្ញុំទទួលខុសត្រូវទៅ ខ្ញុំមិនដែលប្រើបុគ្គលណាដែលងងឹតងងុលទៅធ្វើទេ គ្រាន់តែខ្ញុំឃើញអ្នកដែលប្រាប់ពីលើខ្ញុំអត់បាន ពិចារណាប៉ុណ្ណឹងឯង ។ អីចឹងហេតុផលទាំងនេះ គោលដៅនៃអ្នកព្យាបាលនៅកន្លែងរបស់ខ្ញុំចាប់តាំងពីពេលដែលខ្ញុំទទួលខុសត្រូវ ដូចជាមិនមានហេតុផលអីជាប់គុក ជាប់ច្រវាក់ដោយសារមិនយកចិត្តទុកដាក់ទេ។ ...របបនោះ កាលណាអ្នកឯងធ្វើខុសអី គឺអ្នកត្រូវទទួលខុសត្រូវ...ខ្ញុំមិនហ៊ានខ្ជីខ្ជាទេ ព្រោះខ្លាចងាប់ ដោយសារបក្សថា យើងក្បត់បក្ស អីចឹងខ្ញុំត្រូវតែយកចិត្តទុកដាក់ ។*

## *ឃ.៣. ការអនុវត្តវិជ្ជាពេទ្យ និង ការចាប់ខ្លួនបុគ្គលិកពេទ្យ*

ដើមបណ្តឹងរដ្ឋប្បវេណី **អែម អឿន** បានផ្តល់សក្ខីកម្មថា គាត់បានទទួលវគ្គបណ្តុះបណ្តាល ផ្នែកវេជ្ជសាស្ត្រនៅទីក្រុងភ្នំពេញនៅមន្ទីរពេទ្យលមេសា ក្នុងរយៈពេលប្រមាណជាប្រាំបួនខែ ហើយក្រោយពីនោះមកគាត់បានវិលត្រឡប់ទៅកាន់តំបន់២០ ម្តងម្កាលក្នុងចន្លោះឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា មានអ្នកជំនាញការចិន និងកូរ៉េ ជាអ្នកផ្តល់វគ្គបណ្តុះបណ្តាលក្បួនវេជ្ជសាស្ត្រផ្សេងៗ បូករួមទាំងវិធីសាស្ត្រធ្វើការវះកាត់ ។ លោក **អែម អឿន** បានចងចាំថា នៅពេលនោះ មានសម្ភារៈ ឬបរិក្ខារពេទ្យ ក៏ដូចជា ថ្នាំសង្កូវគ្រប់គ្រាន់នៅក្នុងមន្ទីរពេទ្យដែលគាត់ធ្វើការ ដូច្នេះ គាត់មិនដែលជួបប្រទះនូវបទពិសោធន៍នៃការខ្វះខាតនូវតម្រូវការសំខាន់ៗ សម្រាប់ផ្គត់ផ្គង់ ឬបម្រើការងារផ្នែកវេជ្ជសាស្ត្រឡើយ ។ យោងតាមដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានឲ្យដឹងថា ទាំងបរិក្ខារពេទ្យ និងថ្នាំសង្កូវដែលមានប្រើប្រាស់ គឺនៅសេសសល់ពីរបបចាស់ (**លន់ នល់**) ដោយខ្មែរក្រហមបានប្រមែប្រមូលពីទីតាំងផ្សេងៗគ្នា ហើយយកមករក្សាទុកនៅមន្ទីរពេទ្យមួយចំនួន ។ ទាក់ទងនឹងការអនុវត្តន៍ការវះពិសោធ ដែលលោក **អែម អឿន** បានឃើញជាក់ស្តែង គាត់បានរ៉ាយរ៉ាប់ដូចតទៅនេះ ៖

> *គឺមិនមែនយកខ្មោចមកសាកល្បងទេ គឺមនុស្សតែម្តង ខ្ញុំសួរទៅគេថា ភាគច្រើនជា មនុស្សដែលខាងសន្តិសុខតំបន់គេបញ្ជូនទៅឲ្យពេទ្យតំបន់(២០) ហ្នឹង ។...ខ្ញុំឃើញ ធម្មតាដាក់សេរ៉ូមដៃម្ខាង អ្នកជម្ងឺមុនវះកាត់គេលើកដាក់លើតុវះកាត់ ហើយគេចាប់ផ្តើមឲ្យអ្នកមើលហ្នឹងមិនត្រឹមតែមើលទេ គឺធ្វើជាក់ ស្តែងតែម្តង ។ ចាប់ផ្តើមគឺថា កាត់ ដៃ ឬដកគន្លាក់ដៃ គឺចាប់ផ្តើមធ្វើពីម្រាមដៃរហូតអីចឹងទៅ ដោះវិញបោះចោលអស់។ ដល់អស់ដៃមួយ នៅដៃមួយជាប់សេរ៉ូមហ្នឹងឯង...ពួកអ្នកដែលគេធ្វើហ្នឹង...សូមនិយាយបន្ថែមថា ដោះចេញ (កាត់បំណែកនៃខ្លួនមនុស្ស*

*ចេញពីគ្នា) មនុស្សម្នាក់ ប្រហែលមួយកំណាត់បាវក៏មានខ្លះក៏ដោះដាក់កាធុន រួចខ្ចប់បាវដាក់ដឹកយកទៅចោល ។*

ដើមបណ្ដឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ថា មានការចាក់ថ្នាំស្ពឹកឲ្យសន្លប់ដល់អ្នកជម្ងឺដែល ត្រូវធ្វើការវះកាត់ពិសោធទាំងនោះ ។ ភាគច្រើននៃអ្នកទាំងនេះ គឺសុទ្ធតែជាអ្នកដែលគេរកឃើញថា ជាគិញរបស់ចក្រពត្តិ ពួកសល់ពីកម្ពែលចាស់ ដែលយោងតាមពាក្យស្លោករបស់ខ្មែរក្រហមគឺថា គេចាត់ទុកជាមនុស្ស"ទុកមិនចំណេញ ដកចេញមិនខាត" ។

## *ឃ.៤. វគ្គបំពាក់បំប៉ននយោបាយ*

ដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងថា នៅពេលដែលគាត់បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល ផ្នែកវិជ្ជាពេទ្យនៅទីក្រុងភ្នំពេញប្រមាណជាប្រាំបួនខែនោះ គាត់ក៏បានចូលរួមក្នុងវគ្គបំពាក់បំប៉នផ្នែកនយោបាយ នៅបូរីកីឡាផងដែរ ដែលជាទូទៅត្រូវបានប្រារព្ធធ្វើឡើងម្ដង ឬពីរដងក្នុងមួយខែ និងមានរយៈពេលប្រមាណជាមួយសប្ដាហ៍ទៅ ១០ថ្ងៃ ។ វគ្គខ្លះ អាចមានការចូលរួមប្រមាណជាពីរពាន់នាក់ (២,០០០ នាក់) ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានរម្លឹកពីការចងចាំរបស់គាត់ថា គាត់បានឃើញ **ប៉ុល ពត** (ដែលជាថ្នាក់ដឹកនាំបក្ស និងជាអ្នកដែលបានថ្លែងសុន្ទរកថាមុនគេ) ។ គាត់ឃើញលោកស្រី **យុន យ៉ាត** លោក **នួន ជា** លោក **ខៀវ សំផន** និង លោក **ហ៊ូ នឹម** ។ គាត់មិនច្បាស់នៅក្នុងចិត្តទេថា តើមានវគ្គមានលោក **អៀង សារី** ឬអត់ ក្នុងពេលនោះ ។

សម្រាប់វគ្គនយោបាយនៅបូរីកីឡានេះ "គឺគោលការណ៍របស់បក្ស ប្រហែលជាចង់ឲ្យមានការផ្លាស់ប្ដូររបៀបបក្ស ហៅថា មហាលោតផ្លោះ មហាអស្ចារ្យ" ។ នៅក្នុង "វគ្គឆ្លងកាត់មហាលោតផ្លោះ មហាអស្ចារ្យ" គឺចង់សំដៅទៅលើការបត់បែនខ្លួន (ផ្លូវបត់) ពីបក្សប្រជាធិបតេយ្យឆ្លងទៅកុម្មុយនីស្ត ។ លោក **អែម អឿន** បានថ្លែងយ៉ាងដូច្នេះថា :

> *អីចឹងបើសិនមិត្តណាបត់មិនទាន់ទេ មានន័យថា ឲ្យតែអ្នកឯងបត់មិនទាន់ ឈ្មោះថា ក្បត់ បើសិនជាក្បត់ត្រូវតែកម្ទេច ។ នេះជាភាសា **ប៉ុល ពត** ។ ដល់ពេលលោក **នួន ជា** គាត់មកមានប្រសាសន៍ម្ដងទៀត គាត់និយាយថា អាបត់ហ្នឹង បានមួយៗបន្ទាត់ពីរ បន្ទាត់បន្ដពី **ប៉ុល ពត** បានគាត់ឈានទៅអាបត់មួយទៀតរបស់គាត់ ។ ឯលោកតា **ខៀវ សំផន** ក៏គាត់និយាយថាស្រដៀងគ្នាអីចឹងដែរ ។ ចេះតែបន្ថែមការពិតទៅ យើងមើលទៅ ហាក់ដូចជា គឺថា បើយើងមិនបានដកមកឲ្យដាច់ស្រេចភ្លាមៗទេ ហាក់ដូច ជាខ្លឹមសារទាំងអស់គឺដូចជាតែមួយ ។*

## *ឃ.៥. ការជម្លៀស និង ការចាប់ខ្លួន*

ដើមបណ្ដឹងរដ្ឋប្បវេណីបានរម្លឹកពីការឃើញជនភៀសខ្លួនពីទីក្រុងភ្នំពេញនៅក្នុងតំបន់២០។ ក្រោយពេល "រំដោះ" បានក្នុងឆ្នាំ១៩៧៥ ហើយប្រជាជនដែលជម្លៀសពីភ្នំពេញ ត្រូវបានគេហៅថា ជា "ប្រជាជន ១៧ មេសា" ឬ "ប្រជាជនថ្មី"។ លោក **អែម អឿន** បានរ៉ាយរ៉ាប់ឲ្យដឹងថាមាន "ប្រជាជនចាស់" ខ្លះ ជាពិសេស បើភូមិណាមានផ្ទះទូលាយ គេនឹងដកប្រជាជនចាស់ឲ្យទៅនៅជាមួយបងប្អូនគេធម្មតា "ហើយគេទុកផ្ទះចាស់ហ្នឹង ឲ្យប្រជាជនថ្មីរស់នៅ" ។

លោក **អែម អឿន** បានថ្លែងថា មានបុគ្គលិកពេទ្យខ្លះ ព្រមទាំងអ្នកធ្លាប់ធ្វើកម្មសិក្សាផ្នែកវេជ្ជសាស្ត្រមួយចំនួនផ្សេងទៀត ត្រូវបានចាប់ខ្លួន ។ ចំណែកឯប្រជាជនខ្លះទៀត ត្រូវបានគេចោទប្រកាន់ថា ជាខ្មាំងរបស់បក្ស ហើយអ្នកទាំងនេះ ត្រូវបានគេបញ្ជូន "គឺខ្ញុំឃើញពេលដែលចាប់ដាក់ឡាន មិនដឹងជាគាត់ (ខ្មែរក្រហម) ដោះខោអាវអ្នកទាំងនោះទុកចោលធ្វើអី មិនឲ្យគ្នាទៅឲ្យផុតចាំធ្វើទារុណកម្ម... បើប្រុសវាមិនអីទេ បើស្រីដោះរលីងៗ ខ្ញុំចេះតែឆ្ងល់ ។...បើនិយាយឲ្យអស់សាច់រឿង ប្រហែលជា ខ្ញុំនិយាយអត់រួច ដោយសារអីបង្ហូរទឹកភ្នែក ឃើញពិតនឹងភ្នែក" ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានរម្លឹកទៀតថា ស្ត្រីម្នាក់ឈ្មោះ **ឡេង ស៊ី** (តាមដឹងមកថា ជាប្រពន្ធរបស់សមមិត្ត **ទីវ អុល**) ដែលធ្លាប់ជាអ្នកទទួលបន្ទុកផ្នែកបំពាក់បំប៉នផ្នែកនយោបាយ ត្រូវបានគេសម្រាតសំលៀកបំពាក់ ចេញក្នុងពេលដែលគេមកចាប់ខ្លួនគាត់យកទៅ ។

### *ឃ.៦. ស្ថានភាពបុគ្គលមួយចំនួន និង ជំនឿសាសនា*

ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា នៅក្នុងតំបន់រំដោះមួយចំនួន ក្នុងអំឡុងមុនឆ្នាំ១៩៧៥ ប្រជាជនទូទៅត្រូវបាន "គេរៀបចំចាប់ផ្ដើមដំបូងបង្អស់ គឺរួមគ្នាធ្វើការរបៀបជាការប្រវាស់ដៃគ្នា ក្រោយមកទៀត គេរៀបចំក្រុមនេះឲ្យទៅជាសហករណ៍" ។ លោក **អែម អឿន** បានថ្លែងឲ្យដឹងថា ចាប់ផ្ដើមពីការធ្វើរដ្ឋប្រហារដោយ **លន់ នល់** គាត់បានសង្កេតឃើញមានការបង្កើតក្រុមដាច់ដោយឡែកពីគ្នា រួមមាន "ក្រុមយុវជនស្នេហាជាតិ" ដែលជាក្រុមយុវជនពេញកម្លាំង ឬកម្លាំងស្នូលមួយ និង"ក្រុមមហាជន" សម្រាប់ប្រជាជនទូទៅ ។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានឱ្យដឹងផងថាមាន "ប្រជាជនចម្រើន" ដែលបូករួមទាំង "ប្រជាជនពេញសិទ្ធិ" និង "ប្រជាជនមិនពេញសិទ្ធិ" ។ ចំណែកឯលោក **អែម អឿន** ផ្ទាល់ គឺជាសមាជិកនៃសម្ព័ន្ធយុវជនស្នេហាជាតិមួយរូបផងដែរ "ហើយស្ថានភាពរស់នៅក្នុងពេលនោះ ស្ថិតក្នុងលក្ខខណ្ឌមានសណ្ដាប់ធ្នាប់នៅឡើយ ។ ប្រជាជនទាំងអស់ អាចនិយាយទាក់ទងគ្នាបានដូចប្រក្រតីប្រកបដោយសុជីវធម៌ មានសិទ្ធិសេរីភាពដូចធម្មតា ដោយមិនមានបញ្ហាណាមួយទេ" ។

លោក **អែម អឿន** បានឱ្យដឹងថា ចាប់ពីឆ្នាំ១៩៧៥ "ខ្ញុំចាប់ផ្ដើមងឿងឆ្ងល់" ដោយប្រជាជន ត្រូវបានគេបែងចែកជាបីប្រភេទទៅវិញ មាន "ពេញសិទ្ធិ" មាន "ប្រជាជនត្រៀម" និងប្រភេទប្រជាជនដែលគេកំណត់ថាជា "សត្រូវរបស់បក្ស" ។ ដើមបណ្ដឹងរដ្ឋប្បវេណី **អែម អឿន** បានអធិប្បាយដូចខាងក្រោមនេះ ៖

> *ឈ្មោះថាប្រជាជនពេញសិទ្ធិ...គេហៅប្រជាជនបង្គោល មានន័យថា អ្នកជាប់សម្ព័ន្ធហើយ ។ គេមិនហៅថាយុវជន ឬប្រជាជនតាមភូមិទេ បើនិយាយជាចំហគឺថាជាប្រជាជនចម្រើន គេហៅថាមហាជន។ បើជាប្រជាជនទូទៅពេលនោះ គេហៅថា សមាគមកសិករ ។ មិនមែនស្ម័គ្រចិត្តទេ គេតម្រូវឲ្យចូលជាសមាជិកអង្គការ សមាគមកសិករនេះ ហ្នឹងគេហៅថាប្រជាជនពេញសិទ្ធិ ហើយប្រជាជនទាំងនោះអាចនឹងឆាប់ បានទទួលនាទីក្នុងការងារដែលបក្សតម្រូវឲ្យធ្វើ ។ ឯប្រជាជនអត់សិទ្ធិ គឺស្រេចតែគេប្រើ និយាយឲ្យត្រង់ ។ គ្មានអត់ដែលទទួលតំណែង ឬ ឋានៈតួនាទីធ្វើអីៗ អត់ដែលបានទទួលឡើយ ។*

លោក **អែម អឿន** បានបន្ថែមឲ្យដឹងទៀតថា មានលេខាប្រចាំតំបន់មានចិត្ត "ស្រឡាញ់" ចូលចិត្តគាត់ ហើយលេខាតំបន់រូបនេះ បានជួយបន្លំលាក់ប្រវត្តិរូប ព្រោះតែលេខាបក្សបានដឹងមកថា ឪពុករបស់គាត់មានទំនាក់ទំនងសម្ងាត់ជាមួយនឹងរបបចាស់ (**លន់ នល់**) ។ ទោះយ៉ាងណាក្ដី លោក **អែម អឿន** មិនបានពន្យល់អ្វីស៊ីជម្រៅឡើយ នៅពេលនិយាយមកដល់ចំណុចនេះ ។

ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានបង្ហាញថា ខ្មែរក្រហមបានចេញបញ្ជាឲ្យគាត់ និងយុវជនផ្សេងទៀតទៅ "បំផ្លាញវត្តអារាម" ដូច្នេះគាត់គ្មានជម្រើសទេ បើទោះណាក្នុងវ័យជាយុវជនម្នាក់ លោកគោរពសាសនាព្រះពុទ្ធក៏ដោយ ។ យោងតាមលោក **អែម អឿន** "ការបំផ្លិចបំផ្លាញព្រះពុទ្ធ សាសនា" ត្រូវបានប្រព្រឹត្តទៅច្រើនរូបភាពមួយ គឺហាមមិនឲ្យបួសជាព្រះសង្ឃ និងហាមប្រាមផងដែរ មិនឲ្យមានការសាងសង់ទីវត្តអារាម។ លោក **អែម អឿន** បានលើកពីករណីមុនឆ្នាំ១៩៧៥ "ពិសេសបំផុត គឺនៅក្នុងឆ្នាំ១៩៧៣ និង១៩៧៤ ខ្ញុំចេះឆ្ងល់នៅពេលនោះ ។ បើខ្ញុំមិនធ្វើ ឬ បើខ្ញុំមិនបញ្ជាឲ្យយុវជនខ្ញុំធ្វើ គេនឹងថាខ្ញុំក្បត់បក្ស" ។ គាត់បានបញ្ជាក់ឲ្យដឹងថា ទង្វើនេះ បានកើតមានឡើងក្នុងចន្លោះពីឆ្នាំ១៩៧៣ ទៅឆ្នាំ១៩៧៥ ។

### *ឃ.៧. អាពាហ៍ពិពាហ៍ដោយបង្ខំ*

ដើមបណ្តឹងរដ្ឋប្បវេណី **អែម អឿន** បានថ្លែងឲ្យដឹងថា ខ្មែរក្រហមបានណែនាំគាត់ឲ្យរៀបការជាមួយនារីម្នាក់( យកប្រពន្ធ) ដែលលោក "ចង្អុលចំមនុស្សដែលខ្ញុំអត់ស្រឡាញ់"។ នៅពេលដែលគាត់ប្រកែក ខ្មែរក្រហមបានដាក់ពិន័យលើរូបគាត់ "ទទួលទោស" ដោយបានបញ្ឈប់ពីបម្រើការងារនៅមន្ទីរពេទ្យ ទៅបម្រើការងារនៅឯ "ការដ្ឋានវិញ"។[18] ក្រោយមកទៀត នៅពេលដែលលោក **អែម អឿន** ត្រូវបានភាគីសួរម្តងទៀតថាតើគាត់បានយល់ព្រមរៀបការជាមួយ "ប្រពន្ធរបស់គាត់ទេ" ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានគូសបញ្ជាក់យ៉ាងដូច្នេះ ៖

> *ចុះឡើងៗ ខ្ញុំសម្រេចចិត្តថា ជីវិតរបស់ខ្ញុំ អត់ដឹងថាស្លាប់ ឬរស់ ។ អីចឹង ដាច់ចិត្តបង្ខំ ចិត្តទទួលពាក្យបង្ខំនេះ ថាត្រូវព្រមទទួល។ ប៉ុន្តែការទទួលនេះ ខ្ញុំសូមនិយាយដល់អស់ប្អូនៗ ក្មួយៗឲ្យដឹងឮថា គួរធ្វើយ៉ាងម៉េច ? ទាំងនារីជាភរិយាខ្ញុំ ពេលខ្ញុំដេកចូលដំណេកជាមួយគ្នា បង្ហូរទឹកភ្នែកដាក់គ្នា តើសមនឹងយកគ្នាដែរឬអត់ ?...ហើយយើង សមនឹងរស់បានដែរឬអត់ ?ថ្ងៃនោះគឺខ្ញុំ...*

យោងតាមលោក **អែម អឿន** គាត់ និងប្រពន្ធរបស់គាត់ជឿជាក់ថា ពួកគេគឺស្ថិតនៅក្រោម "គេតាមដានទាំងថ្ងៃទាំងយប់" ហើយអាចនឹងត្រូវសម្លាប់ចោល ប្រសិនណាបើពួកគាត់មិនយកគ្នាជាប្តីប្រពន្ធ ក្រោយពេលនៃការរៀបចំផ្សំផ្គុំនេះ ។ ដោយភាពភ័យខ្លាច ពួកគាត់ទាំងពីរ ក៏សម្រេចរួមរស់ជាមួយគ្នាដោយបង្ខំចិត្ត រហូតបានកូនពីរនាក់ ប្រុសមួយ ស្រីមួយ ។ គូស្វាមីភរិយានេះ នៅតែបន្តរួមរស់ជាមួយគ្នា ទោះក្រោយចប់របបកម្ពុជាប្រជាធិបតេយ្យក្តី ប៉ុន្តែបានលែងលះគ្នា នៅពេលក្រោយមកទៀត ៖ "ដល់ក្រោយមក ខ្ញុំហាក់ដូចជាធ្វើមិនពេញចិត្តគំនិតខ្លួនឯងផង រហូតដល់ប្រពន្ធខ្ញុំគាត់អន់ចិត្ត គាត់សុំលែង ។ នៅក្រោយ១៩៧៩ ហ្នឹងមានសិទ្ធិហើយ ។ យើងក៏បាន លែងលះគ្នា...រហូតដល់ឥឡូវខ្ញុំកសាងគ្រួសារមួយថ្មីហើយ" ។

### *ឃ.៨. អត្តចរិត និងភាពគួរជឿជាក់លើសាក្សី*

លោក **អែម អឿន** បានឆ្លើយសំណួរដែលបានសួរដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងងាយស្រួល។ មានឱកាសមួយចំនួនដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានរម្លឹកក្នុងការគ្រប់គ្រងនូវការឆ្លើយរបស់ខ្លួនកុំឲ្យវែងអន្លាយពេក និងឲ្យចំនឹងប្រធានបទនៃសំណួរ ។ វាច្បាស់ណាស់ថាការចងចាំរបស់គាត់ត្រូវបានរងផលប៉ះពាល់ពីរបបនេះ ជាពិសេស នៅពេលមានការជជែកពិភាក្សាស្តីពីការរៀបការដោយបង្ខំរបស់គាត់ លោក **អែម អឿន** បាននិយាយដូច្នេះថា ៖

*ខ្ញុំនឹងឆ្លើយតាមតែអាចធ្វើទៅបាន តែសូមទោសទុកជាមុនរួចហើយ។ ពេលដែល ខ្ញុំស្រក់ទឹកភ្នែក ដោយសារនឹកឃើញរឿងរ៉ាវពីអតីតកាលទាំងប៉ុន្មាន ។ ថាខ្ញុំចុះជាបុរស ប៉ុន្តែគ្នាជាស្ត្រីក៏ជួបរឿងដូចខ្ញុំដែរ...ទាំងគាត់ ក៏អីចឹង (ប្រពន្ធ) ទាំងខ្ញុំក៏អីចឹង សុទ្ធតែមានរឿងកំសត់លំបាកវេទនានេះ ។ មិនមែនមានន័យថា ខ្ញុំចង់សងសឹកទេ ខ្ញុំចង់ចងកម្មពៀរអីអត់ទេ តែខ្ញុំគ្រាន់តែចង់ដឹងថា អ្នកដែលណែនាំឲ្យគេធ្វើហ្នឹង ទទួលការសង្កត់សង្កិនពីខាងណា? អ្នកណាអ្នកបង្កើតនយោបាយហ្នឹង? បើសិនជានៅតែបណ្តោយឲ្យមានការប្រព្រឹត្តិអញ្ចឹងទៀត តើមានអ្នករងគ្រោះប៉ុន្មានទៀត?*

## ផ្នែកទី ៣៖ បញ្ហាច្បាប់ និងនីតិវិធី

សប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានប្រឈមនឹងបញ្ហានីតិវិធីទ្វេរដង នៅពេលខ្លួនត្រូវតែសម្រេចចិត្ត ថាតើព័ត៌មានថ្មីច្រើនកម្រិតណាដែលគួរតែត្រូវផ្តល់ជូនទៅឲ្យសាក្សី ប្រសិនបើមានភស្តុតាងចង្អុលបង្ហាញពីអំពីជោគវាសនា (ការស្លាប់ ឬរងទុក្ខវេទនាដោយទង្វើជាក់លាក់ណាមួយពីរបបខ្មែរក្រហម) កើតមានឡើងដល់មនុស្សជាទីស្រឡាញ់របស់ពួកគេ ខណៈដែលអង្គជំនុំជម្រះ និងភាគីនានា គឺជាម្ចាស់ឯកសារពាក់ព័ន្ធទាំងនោះ។ នៅពេលដែលមានការសម្រេចចិត្តលើបរិបទដ៏ល្អបំផុតមួយពាក់ព័ន្ធនឹងព័ត៌មានបែបនេះ អង្គជំនុំជម្រះបានទទួលយកមកពិចារណានូវសេចក្តីព្រួយបារម្ភនានា ស្តីពីសុខុមាលភាពបុគ្គលក្នុងនាមជាសាក្សី ចំពោះសិទ្ធិក្នុងការមិនជជីកដេញដោលនូវជីវិតឯកជនរបស់សាក្សីទាំងអស់ ព្រមទាំងភាពពាក់ព័ន្ធនឹងការបរិហារកេរ្តិ៍ផ្សេងៗ (ការបញ្ចេញឲ្យដឹង) នូវកិច្ចដំណើរការនីតិវិធីច្បាប់ផ្សេងៗនៅក្នុងដំណាក់កាលនេះ។

### ក. ការគោរពសិទ្ធិឯកជនរបស់សាក្សី

ក្នុងអំឡុងពេលនៃការសួរដេញដោលទៅកាន់លោក **គឹម វុន** ដោយភាគីសហព្រះរាជអាជ្ញា សាក្សីបានចង្អុលបង្ហាញថា នៅក្នុងឆ្នាំ១៩៧៧ ប្រពន្ធរបស់គាត់ ដែលជាអនុប្រធាននៃការិយាល័យឃោសនាការមិនបានត្រឡប់មកពីវគ្គបំពាក់បំប៉នវិញឡើយ និងត្រូវបានគេចោទប្រកាន់ថាជាភ្នាក់ងារ***ស៊ី.អាយ.អេ***។ លោកបានបង្ហាញឲ្យដឹងបន្ថែមទៀតថា ដោយសារតែមិនមាននរណាម្នាក់ ជូនដំណឹងគាត់ជាមុន ហើយក៏មិនមានការបង្ហាញនូវឯកសារណាមួយបង្ហាញដល់គាត់ ដើម្បីអាចបានដឹងពីទីកន្លែងឃាត់ខ្លួនប្រពន្ធរបស់គាត់ ទើបរហូតមកដល់ពេលនេះ សាក្សីនៅតែមិនបានដឹងថា តើមានអ្វីកើតឡើងចំពោះប្រពន្ធរបស់ខ្លួនឡើយបន្ទាប់ពីការបាត់ខ្លួនតាំងពីក្នុងអំឡុងពេលទៅចូលរួមវគ្គបំពាក់បំប៉ននោះមកម្ល៉េះ។ ឆ្លើយតបចំពោះករណីនេះ ព្រះរាជអាជ្ញាអន្តរជាតិលោក **ខេត រ៉េយន័រ** បានសួរទៅកាន់លោក **គឹម វុន** ដូច្នេះថា "ប្រសិនបើមានឯកសារណាមួយនៅសល់ តើលោកចង់អានដោយផ្ទាល់ភ្នែករបស់លោក ដើម្បីឲ្យលោកស្ងប់អារម្មណ៍ដែរឬទេ អំពីបញ្ហានេះ?" បន្ទាប់ពីការស្នើសុំឲ្យមានការបំភ្លឺនូវសំណួរនេះ ពីសំណាក់លោកប្រធានតុលាការ លោក **រ៉េយន័រ** បានថ្លែងថា ឯកសារដែលលោកកំពុងតែជជែកនេះ គឺជាបញ្ជីកែសម្រួលនៃអ្នកទោសនៅមន្ទីរស-២១។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** គឺលោក **ហ្សាស្តី ប៉ៅ** បានជំទាស់ដោយថ្លែងថា "យើងកំពុងតែមិនបានពិចារណាទៅលើការជំទាស់ផ្លូវច្បាប់" លោកបានបន្ថែមទៀតថា ៖

*វាជាបញ្ហាមនុស្សធម៌ដែលយើងត្រូវតែផ្តល់ជូនសាក្សីនេះនូវឱកាស និងលទ្ធភាពក្នុងការពិចារណា និងពិនិត្យមើលឯកសារនេះជាលក្ខណៈឯកជន មិនមែននៅក្នុងសវនាការ*

*សាធារណៈនោះទេ ។ ការពិតទៅ ប្រសិនបើភាគីព្រះរាជអាជ្ញាគិតពីសុខមាលភាព និងដើម្បីជាប្រយោជន៍ទៅដល់សាក្សីនេះ ត្រូវបង្ហាញគាត់ជាលក្ខណៈឯកជន ដែលជាលក្ខណៈមនុស្សធម៌ចំពោះគាត់ ។*

ក្រុមមេធាវីការពារក្តីរបស់លោក **ខៀវ សំផន** និងក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** ព្រមទាំងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ សុទ្ធតែបានសម្តែងក្តីនូវការយល់ស្របទៅនឹងការលើកឡើងរបស់មេធាវី **ហ្សាស្តី ប៉ៅ** ។ អង្គជំនុំជម្រះក៏បានយល់ស្របតាមការជំទាស់ និងបានចេញសេចក្តីសម្រេចប្រឆាំងនឹងការចង់ដាក់បង្ហាញនូវបញ្ជីអ្នកទោស ដែលបានកែប្រែរួចមកហើយនេះ ជាមួយនឹងការណែនាំដូចខាងក្រោម ៖

*ជាការសមស្របណាស់ដែលការបង្ហាញឯកសារប្រភេទនេះ ចំពោះសាក្សី ជាលក្ខណៈឯកជន ហើយគួរតែត្រូវបានធ្វើតាមរយៈអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ។ ដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យដាក់បង្ហាញឯកសារសាក្សីនេះ ជូនទៅសាក្សីនៅពេលនេះទេ ។*

## ខ. ការប្រើឯកសារធ្វើជាមូលដ្ឋានដើម្បីតាំងសំណួរទៅកាន់សាក្សី

សប្តាហ៍មុន សំណួរដែលកំពុងកើតឡើងជាថ្មីម្តងទៀត គឺថាតើភាគីនៃសំណុំរឿងទាំងអស់ គួរតែដើរផ្លូវណា ទាក់ទងនឹងបែបបទនៃការបង្ហាញឯកសារនានា ដើម្បីធ្វើការសួរដេញដោលទៅកាន់សាក្សី ប៉ុន្តែអង្គជំនុំជម្រះកំពុងតែពន្យារពេលក្នុងការដោះស្រាយបញ្ហានីតិវិធីមួយនេះ ដោយបានប្រកាសថា បញ្ហានេះ នឹងត្រូវលើកយកទៅពិចារណាក្នុងអំឡុងពេលនៃកិច្ចប្រជុំ ស្តីពីការគ្រប់គ្រងសវនាការដែលគ្រោងធ្វើឡើងនៅថ្ងៃទី១៧ ខែសីហា ខាងមុខនេះ ។ បញ្ហាដែលងើបឡើងវិញនៅក្នុងសប្តាហ៍នេះគឺនៅពេលលោកមេធាវី **ហ្សាស្តី ប៉ៅ** បានជំទាស់ទៅនឹងសេចក្តីយោងរបស់ព្រះរាជអាជ្ញាអន្តរជាតិ **ខេត រ៉េយន័រ** ដែលបានប្រើប្រាស់នូវការដកស្រង់ខ្លឹមសារមួយចំនួនចេញពី *ទស្សនាវដ្តីទង់បដិវត្តន៍* ក្នុងពេលសួរដេញដោលទៅកាន់សាក្សី **គឹម វុន** ក្រោមហេតុផលថា រាល់ភាគីសំណួរទាំងអស់ ជាការចាំបាច់ក្នុងការឆ្លុះបញ្ចាំងនូវការធ្លាប់ជួបប្រទះ ឬបង្ហាញឲ្យឃើញពីការទទួលដឹងឮពីដំបូងទីរបស់សាក្សី ចំពោះឯកសារណាមួយដែលត្រូវប្រើប្រាស់ជាមូលដ្ឋាននៃការសួរសំណួរទៅកាន់រូបគាត់ ។ វាបង្ហាញឲ្យឃើញថាបញ្ហានេះ ជាការពិតណាស់ត្រូវបានដោះស្រាយក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំគ្រប់គ្រងសវនាការ ដូចដែលអង្គជំនុំជម្រះបានធ្វើសេចក្តីសម្រេចប្រឆាំងទាស់នឹងការលើកឡើងរបស់លោក **ហ្សាស្តី ប៉ៅ** ហើយលោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានធ្វើការក្រើនរម្លឹកដូចខាងក្រោម ៖

*ខ្ញុំសូមព្យាយាមរម្លឹកនូវអ្វីដែលខ្ញុំបាននិយាយនៅក្នុងកិច្ចប្រជុំសវនាការ គឺថាក្នុងករណីឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ភាគីទាំងអស់ អាចប្រើប្រាស់ឯកសារណាមួយនោះបាន ដោយយើងអាចយកតែខ្លឹមសារសម្រាប់ជាមូលដ្ឋាននៃការតាំងសំណួរ ហើយឯកសារនោះ អាចដាក់ជូនសាក្សីបាន ។ ប្រសិនបើ នៅពេលបង្ហាញទៅខ្លឹមសារណាមួយ អាចនាំឲ្យលោកប្រធានយល់ឃើញថា ឯកសារនោះ អាចជះឥទ្ធិពលដល់ចម្លើយសាក្សីនោះ គឺយើងត្រូវតែដកឯកសារនោះចេញពីមុខសាក្សី ។ ប៉ុន្តែ ប្រសិនបើសាក្សីដឹង ឬស្គាល់ហើយក៏ធ្លាប់ឃើញឯកសារនេះ យើងមិនចាំបាច់ដកឯកសារនោះចេញពីមុខសាក្សី ឬដកចេញពីអេក្រង់ទូរទស្សន៍នោះទេ ។*

## គ. ភាពសមរម្យនៃការសួរនាំអំពីប្រតិបត្តិការណ៍សម្ភាសន៍របស់បុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងវគ្គមានសាក្សី

ក្នុងពេលធ្វើសក្ខីកម្មរបស់សាក្សី **ស សៀក** លោកមេធាវី **ហ្សាស្ទី ប៉ៅ** បានបង្ហាញពីចេតនារបស់ក្រុមមេធាវីការពារក្តីរបស់លោក **នួន ជា** ដែលស្នើសុំផ្នែកខ្លះនៃកិច្ចសម្ភាសន៍ដែលអ្នកស្រីបានផ្តល់ឲ្យមន្ត្រីបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងបំណងដើម្បីធ្វើការចង្អុលបង្ហាញឲ្យឃើញថា ព័ត៌មានខ្លះនៃបទសម្ភាសន៍ទាំងនោះ "ភាគច្រើនត្រូវបានគេប្រាប់ទៅដល់សាក្សី ហើយបើទោះបីថា ក្រោយពីពេលហ្នឹងមកបីឆ្នាំមកហើយក៏ដោយ (ក្រោយកិច្ចសម្ភាសន៍) ក៏សាក្សីនៅតែអាចផ្តល់សក្ខីកម្មបានដែរ សូម្បីតែគាត់មិនបានដឹងពីបញ្ហាទាំងនេះក្នុងអំឡុងពេលនោះ ក៏គាត់ឆ្លើយបានដែរ"។ ព្រះរាជអាជ្ញាអន្តរជាតិ លោក **ថារិក អាប់ឌុល**ហាក់បានតវ៉ាថា "ការបញ្ចេញមតិយោបល់បែបនេះ" នៅចំពោះមុខសាក្សី គឺជាការ "មិនសមស្រប" និងថាវាហាក់ដូចជាការបញ្ជាក់ ឬ ក៏ជាការប្រាប់ទៅដល់សាក្សីដូច្នេះដែរឲ្យឆ្លើយតាមអ្វីៗ ស្របតាមខ្លឹមសារនៃបទសម្ភាសន៍ពីមុនរបស់អ្នកស្រី" ។ ឆ្លើយតបនឹងបញ្ហានេះ លោកប្រធានតុលាការបានធ្វើការណែនាំដល់ភាគីនៃសំណុំរឿងទាំងអស់ ដែលប៉ុនប៉ងចង់ធ្វើសេចក្តីថ្លែងការណ៍អ្វីមួយ ឬចង់ដាក់នូវសំណើផ្សេងៗ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីណាម្នាក់នោះ ភាគីត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមវិធានផ្ទៃក្នុងនៃ **អ.វ.ត.ក** គឺវិធាន៩២ ។

## ឃ. សំណួរដែលពុំមានភាពពាក់ព័ន្ធ ឬនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១

សប្តាហ៍នេះ ប្រធានតុលាការ លោកចៅក្រម **និល ណុន** បានធ្វើការណែនាំម្តងហើយម្តងទៀត ដល់ភាគីឲ្យព្យាយាមរៀបចំសំណួររបស់ខ្លួនឲ្យស្ថិតក្នុងដែនវិសាលភាពនៃសវនាការវគ្គដំបូងនេះ ។ កាលពីថ្ងៃចន្ទ លោកប្រធានបានធ្វើការទូន្មានដល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺកញ្ញា **បេនី យេ** ឲ្យកំណត់នូវសំណួររបស់ខ្លួនត្រឹមអង្គហេតុនៃសំណុំរឿង០០២/០១ ដោយផ្តោតសំខាន់ទៅលើរឿងរ៉ាវដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីមួយ និងទីពីរនៅពេលដែលមេធាវីរូបនេះ បានព្យាយាមសួរសំណួរទៅកាន់សាក្សី **ស សៀក** អំពីការផ្ទេរអ្នកស្រីឲ្យទៅរស់នៅក្នុងតំបន់ដីក្រហមដើម្បីធ្វើការលត់ដំកែប្រែ ។

គួរកត់សម្គាល់ថា តំបន់ដីក្រហមត្រូវបានលើកឡើងជាហូរហែក្នុងពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមួយរូបឈ្មោះ **អ៊ុង ចុងហឿង** បានចូលខ្លួនមកផ្តល់សក្ខីកម្ម កាលពីថ្ងៃទី០៨ ខែសីហា[19] ហើយវាអាចទៅរួចដែលអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ មានសេរីភាពក្នុងការសួរដេញដោលនូវអង្គហេតុនានាដោយទាញចេញពីសក្ខីកម្មរបស់សាក្សីរូបនេះព្រោះថា លោក **អ៊ុង ចុងហឿង** បច្ចុប្បន្នមានទីលំនៅក្នុងប្រទេសបែលហ្ស៊ិក។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីណាមួយនោះ វានឹងមានអត្ថប្រយោជន៍ប្រសិនបើអង្គជំនុំជម្រះផ្តល់នូវការណែនាំជាក់លាក់ទៅលើដែនកំណត់ថា តើត្រឹមណាដែលអាចអនុញ្ញាតឲ្យធ្វើបានចំពោះការសួរដេញដោលលើសាក្សី ដែលការធ្វើបែបនេះគឺដើម្បីឱ្យភាគីអនុវត្តតាមផ្អែកលើការណែនាំទាំងនោះ ។

### ង.	ការជ្រើសតាំងអ្នកតំណាងសម្រាប់ភាគីនីមួយៗ ក្នុងការសួរដេញដោល

កាលពីថ្ងៃព្រហស្បតិ៍ ដើមបណ្តឹងរដ្ឋប្បវេណីលោក **អែម អឿន** បានចាប់ផ្តើមផ្តល់សក្ខីកម្ម ខណៈពេលនោះ លោកប្រធានតុលាការបានរម្លឹកភាគីថា ក្នុងអំឡុងពេលនៃកិច្ចប្រជុំស្តីពីការគ្រប់គ្រងសវនាការដែលបានធ្វើឡើងនៅថ្ងៃទី១៧ ខែសីហា អង្គជំនុំជម្រះមានបំណង "លើកទឹកចិត្តដល់ភាគីទាំងអស់ ឲ្យធ្វើការចាប់តាំងតំណាងមួយរូបពីក្រុមរបស់ខ្លួននីមួយៗ ដើម្បីតាំងសំណួរដេញដោលទៅកាន់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី ក្នុងន័យដើម្បីចៀសវាងនូវសំណួរច្រំដែល ឬនាំឲ្យបាត់បង់នូវពេលវេលា និងដើម្បីឲ្យការប្រើប្រាស់ពេលវេលាហ្នឹងមានប្រសិទ្ធភាព ប្រព្រឹត្តទៅឆាប់រហ័ស"។ លោកប្រធានតុលាការបានចង្អុលបង្ហាញថា មកដល់ពេលនេះ មានតែមេធាវីក្រុមការពារក្តីរបស់លោក **អៀង សារី** តែប៉ុណ្ណោះដែលបានអនុវត្តនូវវិធីសាស្ត្រនេះ។

ជាការឆ្លើយតប មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **គ្រីស្ទីន ម៉ាទីណូ** បានបង្ហាញយ៉ាងជាក់ច្បាស់ថា មេធាវីនាំមុខជាតិតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី លោក **ពេជ អង្គ** ព្រមទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិមួយរូបទៀត គឺលោក **គឹម ម៉េងឃី** "ជាអ្នកសួរដើមបណ្តឹងរដ្ឋប្បវេណីនេះ ព្រោះដោយសារតែការនិយាយភាសាខ្មែរវាមិនមានភាពងាយស្រួល កុំឲ្យមានបញ្ហាក្នុងការបកប្រែ" ។

## ផ្នែកទី ៤៖	ការគ្រប់គ្រងសវនាការ

អង្គជំនុំជម្រះសាលាដំបូង (ដោយមានជំនួយពីអង្គភាពគាំពារសាក្សី និង ជនរងគ្រោះ) បានបន្តការអនុវត្តនូវការយកចិត្តទុកដាក់ក្នុងការបំពេញមុខងារខ្លួនគួរឲ្យកោតសរសើរ ដើម្បីធានាឲ្យមានសាក្សីបម្រុងដើម្បីជាមធ្យោបាយឆ្លើយតបនឹងការពន្លឿននូវភាពចាំបាច់នៃកិច្ចដំណើរការនីតិវិធី ។ នៅថ្ងៃចន្ទ សាក្សី **ស សៀក** ត្រូវបានត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់សក្ខីកម្ម នៅពេលដែលសាក្សី **សួង ស៊ីគឿន** បានស្នើសុំពន្យារពេលផ្តល់សក្ខីកម្ម ដោយហេតុផលសុខភាពទន់ខ្សោយរបស់គាត់។ អង្គជំនុំជម្រះ ក៏អាចកោះហៅសាក្សី **គឹម វុន** ភ្លាមៗ ឲ្យចូលខ្លួនមកផ្តល់សក្ខីកម្ម បន្ទាប់ពីសាក្សី **ស សៀក** បានបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់កាលពីថ្ងៃអង្គារ ។ លើសពីនេះទៅទៀត លោកប្រធានតុលាការ បានបន្តនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីជួយសម្រួលដល់ការចាត់ចែងគ្រប់គ្រងដំណើរការនីតិវិធី ដោយបានធ្វើអន្តរាគមន៍ នៅពេលដែលភាគីបានសួរនូវសំណួរច្រំដែល ឬមិនពាក់ព័ន្ធ។ លោកប្រធានក៏បានលើកទឹកចិត្តភាគី ធ្វើការជ្រើសតាំងតំណាងម្នាក់ៗពីក្រុមរបស់ខ្លួននីមួយៗ ដើម្បីធ្វើការសួរដេញដោលសាក្សី ។

### ក.	វត្តមាន

ដូចគ្នានឹងករណីដែលបានកើតឡើងកាលពីប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ជនជាប់ចោទ **អៀង សារី** បានបន្តចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងខាងក្រោម។ លោក **នួន ជា** ក៏មានបញ្ហាសុខភាពទន់ខ្សោយ និងបានលះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមានដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការរៀងរាល់ពេលរសៀលនៃវគ្គដំណើរការនីតិវិធីសវនាការ ។ មានតែលោក **ខៀវ សំផន** ទេ ដែលបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការបានពេញលេញក្នុងសប្តាហ៍នេះ ។

**វត្តមានដើមបណ្តឹងរដ្ឋប្បវេណី ៖** ពេញមួយសប្តាហ៍នេះ មានដើមបណ្តឹងរដ្ឋប្បវេណីប្រមាណពី ២០ ទៅ ៣០នាក់ មានវត្តមាននៅក្នុងបន្ទប់សវនាការ និងសាលសាធារណជន ។

**ការចូលរួមរបស់សាធារណជនក្នុងសប្តាហ៍នេះ ៖** សវនាការបានបន្តប្រព្រឹត្តទៅនៅសប្តាហ៍ នេះ ដោយមានការចូលរួមតាមដានយ៉ាងច្រើនកុះករពីសាធារណជន ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីផ្នែកកិច្ចការសាធារណៈនៃ **អ.វ.ត.ក** ។

| កាលបរិច្ឆេទ | សវនាការវគ្គពេលព្រឹក | សវនាការវគ្គរសៀល |
|---|---|---|
| **ថ្ងៃចន្ទ**<br>*២០/០៨/២០១២* | • មានប្រជាជនមកពីខេត្តកំពង់ឆ្នាំង ប្រមាណជា ៣០០ នាក់ បូករួមទាំងជនជាតិភាគតិចចាមមកពីស្រុករលាផ្អៀផង ដែរ បានចូលរួមតាមដានសវនាការ ។ | • មាន ២០០ នាក់ ជាប្រជាជនមកពីស្រុកសំរោង ខេត្តតាកែវ ព្រមទាំងប្រជាជនមកពីស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ បានចូលរួម ។<br>• មានអ្នកឃ្លាំមើលជាតិ និង អន្តរជាតិ មួយចំនួនទៀត ក៏បានចូលរួម ។ |
| **ថ្ងៃអង្គារ**<br>*២១/០៨/២០១២* | • មានប្រជាពលរដ្ឋប្រមាណជា ៣០០ នាក់ មកពីខេត្តសៀមរាប និង ខេត្តកំពង់ចាមបានចូលរួម។ | • មានប្រជាជនប្រមាណជា ១០០នាក់ មកពីស្រុកបាធាយ ខេត្តកំពង់ចាម បានចូលរួម ។ |
| **ថ្ងៃពុធ**<br>*២២/០៨/២០១២* | • មានប្រជាជនមកពីភូមិ និង ឃុំខ្វាវ ខេត្តតាកែវ ប្រមាណជា ៣០០ នាក់ បានចូលរួម ។<br>• មានក្រុមអ្នកឃ្លាំមើលជាជនបរទេសមួយចំនួន ដឹកនាំដោយអង្គការ *ស្ការកម្ពុជា* បានចូលរួម។ | មានប្រជាជនប្រមាណជា ២៥០ នាក់ មកពី ខណ្ឌដង្កោ និង មកពីស្រុកអង្គស្នួល ខេត្តកណ្តាល បានចូលរួម ។ |
| **ថ្ងៃព្រហស្បតិ៍**<br>*២៣/០៨/២០១២* | • មានប្រជាជនប្រមាណ ៣៥០នាក់ មកពីខេត្តព្រៃវែង បានចូលរួម ។<br>• មានក្រុមនិសិត្ស *លីហ្គលគ្លីនិក* (Legal Clinic) នៃសាកលវិទ្យាល័យ *ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច* ចំនួន ២០នាក់ បានចូលរួម ។ | • មានប្រជាជនប្រមាណជា ២៥០ នាក់ មកពីស្រុកបាធាយ ខេត្កំពង់ចាម បានចូលរួម ។<br>• មានក្រុមនិសិត្ស *លីហ្គលគ្លីនិក* (Legal Clinic) នៃសាកលវិទ្យាល័យ *ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច* ចំនួន ២០នាក់ បានចូលរួម ។ |

## ខ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃចន្ទ ២០/០៨/១២ | ៩:០១ | ០៩:៣៧-១០:៥៧ | ១២:០៦-១៣:៣១ | ១៤:៤១-១៥:០១ | ១៦:០៨ | ៥ម៉និង ០២នាទី |
| ថ្ងៃអង្គារ ២១/០៨/១២ | ៩:០០ | ១០:៣៧-១០:៥៨ | ១២:០៤-១៣:៣២ | ១៤:៤៣-១៥:០២ | ១៦:១២ | ៥ម៉និង ៤នាទី |
| ថ្ងៃពុធ ២២/០៨/១២ | ៩:០០ | ១០:៣៣-១០:៥០ | ១២:០៥-១៣:៣៤ | ១៤:៤២-១៥:០២ | ១៦:០៣ | ៤ម៉និង ៥៧នាទី |
| ថ្ងៃព្រហស្បតិ៍ ២៣/០៨/១២ | ៩:០៣ | ១០:២៤-១០:៤២ | ១២:០៣-១៣:៣១ | ១៤:៤១-១៥:០១ | ១៦:១១ | ៥ម៉និង ០២នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៥ម៉ោង និង០២នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *២០ ម៉ោង និង០៥នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និង សប្តាហ៍នៃសវនាការ* | | | | *៤៤០ម៉ោង និង២៩នាទី* | | |
| *រយៈពេលសវនាការចំនួន ១០០ ថ្ងៃ អំឡុងពេល ២៩ សប្តាហ៍* | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

*AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok. This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Pavithra Prakash Nair, Noyel Ry, Sovanna Sek, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center rand the War Crimes Studies Center.

[1] Soung Sikouen stated that the *Black Book* was originally written in Khmer then translated into English and French; thus, he expressed curiosity when Karnavas recounted Witness Ong Thong Hoeung's testimony on 9 August, alleging that Hor Namhong and Pich Bunthan spent almost a day trying to translate the book into Khmer in BoengTrabek.

[2] Saloth Ban testified before the Trial Chamber from 23 April to 3 May 2012. *See* CASE 002 KRT TRIAL MONITOR. Issue No. 20, Hearing on Evidence Week 15 (23-26 April); and CASE 002 KRT TRIAL MONITOR. Issue No. 21, Hearing on Evidence Week 16 (30 April, 2-3 May 2012).

[3] CASE 002 KRT TRIAL MONITOR, Issue No. 31, Hearing on Evidence Week 26 (6-9 August 2012). 4.

[4] Suong Sikoeun confirmed that, when Ieng Sary instructed him to write his biography, Ieng Sary did not tell him that Ros Sarin implicated him. The Witness only read Ros Sarin's confession in 2010 when he visited TuolSleng Museum.

[5] Rochoem Ton alias "Cheam" and "Phy Phuon" was a former high-ranking Ministry of Foreign Affairs cadre who testified before the Chamber from 25 July to 2 August.*See* CASE 002 KRT TRIAL MONITOR, Issue No. 29, Hearing on Evidence Week 24 (23-26 July); and CASE 002 KRT TRIAL MONITOR, Issue No. 30, Hearing on Evidence Week 25 (30-31 July, 1-2 August 2012).

[6] Sa Siek was questioned by international Prosecutor Mr. Tarik Abdulhak, followed by Civil Party lawyer Ms. Beini Ye and national CPLCL Mr. Pich Ang. Subsequently, she was examined by Judge Jean-Marc Lavergne, Nuon Chea's counsels, Mr. Jasper Pauw and Mr. Son Arun; IengSary's Counsel, Mr. Michael Kanavas; and Khieu Samphan's counsels, Mr. Kong Sam Onn and Ms. Anta Guissé.

[7] Tiv Ol, together with Hou Nim, was a head of the Art Unit. See CASE 002 KRT TRIAL MONITOR, Issue No. 32, Hearing on Evidence Week 27 (13-16 August 2012). 7-9. TivOl was among the prisoners of S-21. OCIJ. "Closing Order" (15 September 2010). D427 [hereinafter **CLOSING ORDER**]. Note 1857, D288/6.68.1, Annex 1: Revised S-21 Prisoner List.

[8] "Chit Ros" is spelled phonetically. It is also referred to as Ath Ros Mountain.

[9] Sa Siek was asked regarding the following speeches: (i) Khieu Samphan's statement on the current situation (no title given), dated 1 April 1975, with English ERN 00166897 to 98; (ii) *Khieu Samphan is Congratulating the FPLNK*, which was read by a broadcaster, dated 3 April 1975, with English ERN 00166923 to 25; (iii) *Khieu Samphan's Denial,* 8 April 1975, with English ERN 00166927; (iv) *Khieu Samphan is Calling the Phnom Penh Population to Rally the FUNK*, dated 14 April 1975, with English ERN 006948 to 49); (v) *Khieu Samphan's Congratulatory Message,* dated 22 April 1975, with English ERN 00166994 to 96; 6.) *Press Release from the Special National Congress of Cambodia That Convened from 25 to 27 April 1975,* which statement is attributed to Khieu Samphan, with English ERN 00167012 to 13.

[10] Sa Siek reportedly met Khieu Samphan's wife in Office 808 but they did not have any personal interactions. The Witness moreover stated that, although she did not know Khieu Samphan's wife personally, in 2010, the latter visited her house and asked her whether Khieu Samphan had ever been to the propaganda unit.

[11] Witness was examined by the following: national Prosecutor Mr. Veng Hout; international Prosecutor Mr. Keith Raynor; Civil Party lawyer Ms. Beini Ye; Judge Jean-Marc Lavergne; Khieu Samphan's counsels, Mr. Kong Sam Onn and Ms. Anta Guissé; Nuon Chea's counsels, Mr. Son Arun and Mr. Jasper Pauw; and Ieng Sary's counsel, Mr. Michael Karnavas

[12] Veng Hout observed that Kim Vun's OCIJ statement stated differently and said, "In your statement through the investigators you indicated that you were 12 at that time." Veng Hout did not pursue this matter and proceeded with his next question.

[13] "According to Nuon Chea, the publication was later renamed and printed in typeset after the "liberation" in
KRT Trial Monitor Case 002! Issue No. 33! Hearing on Evidence Week 28! 20-23 August2012
171975, when the KR leadership gained access to printing presses. Nuon Chea testified that Revolutionary Flag had a cover depicting an image of one flag. The later incarnation of the publication, published and disseminated as Red Flag, featured an image of five flags on the cover." See CASE 002 KRT TRIAL MONITOR, Issue No. 8, Hearing on Evidence Week 3 (10-12 January 2012).

[14] Based on the Closing Order, Borei Keila (also referred to as K-6) was a meeting place where mass political trainings on policies of the CPK were given to Party cadres and workers in Phnom Penh. CLOSING ORDER.Para. 59 and 886.

[15] Em Oeun's alias is spelled phonetically. He was examined by national CiviI Party lawyer Mr. Kim Mengkhy and national CPLCL Mr. PichAng.

[16] Witness also described his main duty as that of a "medic."

[17] Witness explained that sector 20 was a "Khmer Rouge liberated zone" in the East Zone. CASE 002 KRT TRIAL MONITOR, Issue No. 31, Hearing on Evidence Week 26 (6-9 August 2012). 9.

[18] He was later transferred back to the hospital, as the number of patients there necessitated his return.

[19] CASE 002 KRT TRIAL MONITOR, Issue No. 31, Hearing on Evidence Week 26 (6-9 August 2012). 9.